ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 30-May-2013, 15:13
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៣**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី១៨៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ត់

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ
*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកកែន
*(Mr. Arthur VERCKEN)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ទី ស្រ៊ុនណា

លោក ប៉ាស្កាល់ អូប៊ីង
*(Mr. Pascal AUBOIN)*

លោក ម៉ះដេវ ម៉ូហាន *(Mr. Madhev MOHAN)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
| --- | --- |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក ម៉ះដេវ ម៉ូហាន | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ខៀវ សំផន | ខ្មែរ |
| លោក ថៅ នី (TCCP-187) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ចៅ នី** (TCCP-187)

ស្ទួរដោយប្រធានអង្គជំនុំ ផ្តើមពី៖ .................... ទំព័រ ៤
សួរដោយលោក អាកទូរ វែកគែន ផ្តើមពី៖ .................... ទំព័រ ៥
សួរដោយលោក អាប់ឌុលឡាក់ ថារីក ផ្តើមពី៖ .................... ទំព័រ ១៥
សួរដោយលោក ម៉ះដេវ ម៉ូហាន ផ្តើមពី៖ .................... ទំព័រ ២០
សួរដោយលោក ពេជ អង្គ ផ្តើមពី៖ .................... ទំព័រ ២៤

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅក្នុងថ្ងៃនេះ គឺនៅព្រឹកនេះអង្គជំនុំជម្រះសាលាដំបូងធ្វើសវនាការស្តាប់នូវសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ថៅ នី បន្ថែមតាមសំណើសុំរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ចុះថ្ងៃទី០៧ ខែធ្នូ២០១២ ឯកសារ E250 និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ ឯកសារ E267/3។

ហើយដោយដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ធ្លាប់បានមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនេះម្តងរួចមកហើយ លើអង្គហេតុនៃសំណុំរឿង០០២/០១ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២ ដែលមានប្រតិចារឹក ឯកសារ E146.1។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យភាគសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនូវអង្គហេតុពាក់ព័ន្ធដែលគាត់បានផ្តល់សក្ខីកម្មរួចហើយនោះឡើយ។

[០៩:០៣:៤៦]

ភាគីអាចសួរតែអង្គហេតុថ្មីដែលមិនទាន់បានសួរគាត់ នៅកាលពីសវនាការលើកមុនប៉ុណ្ណោះ ហើយអង្គហេតុនោះកើតឡើងមាននៅចុងនៃសវនាការលើកមុន ដោយគាត់បានយកនូវវេទិកាដែលអង្គជំនុំជម្រះផ្តល់ជូនគាត់ឲ្យថ្លែងអំពីទុក្ខសោកវេទនា គាត់បានលើកឡើងនូវអង្គហេតុមួយថ្មីទៀត ដែលបញ្ហានេះអង្គជំនុំជម្រះមិនបាន មិនមានលទ្ធភាពក្នុងការធ្វើសវនាការឲ្យបានចប់សព្វគ្រប់នៅពេលនោះ ហើយដោយសារមានការតវ៉ា អង្គជំនុំជម្រះក៏បានសម្រេចដូច្នេះ។ ហើយអង្គជំនុំជម្រះគឺលើកទឹកចិត្តផ្តោតការសួរដេញដោលនេះ ទៅលើបញ្ហាដែលមេធាវីការពារក្តី ខៀវ សំផន បានស្នើសុំនេះតែប៉ុណ្ណោះ។

ហើយការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋនាពេលនេះ អង្គជំនុំជម្រះសាលាដំបូងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ខៀវ សំផន តាំងសំណួរដេញដោលមុនភាគីដទៃទៀត ហើយនិងមានរយៈពេលមួយវគ្គនៃសវនាការនៅព្រឹកនេះ។

សូមអញ្ជើញលោកមេធាវី!

[០៩:០៥:០២]

**លោក អាកឡូរ វែកគែន៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម។ ខ្ញុំចង់ចោទសួរអំពីបញ្ហាស្របច្បាប់នៃលំដាប់លំដោយដែលលោកប្រធានទើបតែបញ្ជាក់ជូនអម្បាញ់មិញនេះ។ ពីព្រោះថាតាមលំដាប់លំដោយធម្មតានៃការសួរដើមបណ្ដឹងរដ្ឋប្បវេណីនោះ គឺវាខុសពីអ្វីដែលលោកប្រធានបានប្រាប់អម្បាញ់មិញនេះ។ ព្រោះថាធម្មតា គឺមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីជាអ្នកសួរមុន ហើយបន្ទាប់មកសហព្រះរាជអាជ្ញា និងជាចុងក្រោយគឺមេធាវីការពារក្ដី។

ដូច្នេះខ្ញុំសូមរំឭកជូនអង្គជំនុំជម្រះថា យើងពិតជាអ្នកស្នើសុំឲ្យដើមបណ្ដឹងនេះមកមែន ប៉ុន្តែមិនមែនជាសាក្សីរបស់យើងទេ។ យើងស្នើសុំឲ្យត្រឡប់មកវិញនេះ ពីព្រោះថានៅពេលដែលបុគ្គលនោះបានថ្លែងអំពីការឈឺចាប់របស់ខ្លួន គាត់បានលើកឡើងនូវអង្គហេតុថ្មីមួយភ្លាមៗនោះ។ ហើយនៅពេលនោះ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យយើងខ្ញុំសួរសំណួរដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះអំពីអង្គហេតុថ្មីនោះទេ។ ពេលនោះគឺមេធាវី អង់តា ហ្គីសសេ គាត់ជាអ្នកអន្តរាគមន៍ ហើយលោកប្រធានបានបញ្ជាក់ថាសាក្សីត្រឡប់ទៅផ្ទះវិញហើយ។

[០៩:០៦:១៩]

ដូច្នេះខ្ញុំគិតថា សូមឲ្យអង្គជំនុំជម្រះអនុវត្តទៅតាមលំដាប់លំដោយធម្មតាដូចសព្វដង។ ការធ្វើបែបនេះគឺដើម្បីជួយសម្រួលការងារ។ ខ្ញុំសូមផ្ដល់ឧទាហរណ៍មួយ ខាងដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ញើអ៊ីម៉ែលមកជូនខាងយើងខ្ញុំកាលពីម្សិលមិញ ដោយមានជាសំណួរដែលខ្លួនចង់សួរនៅក្នុងសវនាការ។ ហើយនៅក្នុងនោះយើងឃើញមានអង្គហេតុថ្មីមួយទៀតហើយដែលលេចឡើង ដែលដើមបណ្ដឹងរដ្ឋប្បវេណីគាត់មិនបានលើកឡើងនៅក្នុងសវនាការនោះទេ។ គឺគាត់និយាយថា អីវ៉ាន់របស់គាត់នោះត្រូវបានគេហៅតាមវិទ្យុឲ្យមកវិញ។

ដូច្នេះដើម្បីកុំឲ្យខាតពេល គឺថាសុំឲ្យខាងដើមបណ្ដឹងរដ្ឋប្បវេណីសួរសំណួរទៅកូនក្ដីរបស់គាត់ទៅ ហើយឲ្យសហព្រះរាជអាជ្ញាបន្ត ហើយចុងក្រោយគឺខាងមេធាវីការពារក្ដី ដើម្បីឲ្យយើងដឹងអំពីទ្រង់ទ្រាយពិតប្រាកដនៃសក្ខីកម្មរបស់គាត់ពាក់ព័ន្ធទៅនឹងអង្គហេតុថ្មីៗ ដែលគាត់លើកឡើងនោះ។

ដូច្នេះជាការសមហេតុសមផលណាស់ ដើម្បីរក្សាពេលវេលាឲ្យចំណេញទាំងអស់គ្នានោះ គឺថាសុំឲ្យអង្គជំនុំជម្រះនៅតែរក្សាលំដាប់លំដោយធម្មតា តាមការអនុវត្តដូចសព្វមួយដងវិញ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[០៩:០៨:០៨]

**លោក ម៉ះដេវ ម៉ូហាន៖**

សូមគោរពលោក លោកស្រីចៅក្រម។ លោកប្រធាន យើងខ្ញុំសូមជម្រាបថានីតិវិធីដែលបានរៀបរាប់ដោយចៅក្រមនោះ គឺថាត្រូវគោរព។ ដូច្នេះគឺយើងខ្ញុំស្នើថាឲ្យមេធាវីគោរពទៅតាមសេចក្តីសម្រេច។ យើងមានមូលហេតុបី: ទី១ គឺតាមពិតគឺត្រូវបានទទួលដោយស្គាល់មេធាវីការពារក្តីហើយមូលហេតុដែលដើមបណ្តឹងរដ្ឋប្បវេណីដែលបាននេះ គឺថាមិនទៅតាមនីតិវិធីទូទៅទេ គឺថាគាត់បានផ្តល់ភស្តុតាងពីខែវិច្ឆិការួចហើយ។ គឺថា -- ប៉ុន្តែមេធាវីការពារក្តីទេថាមានអង្គហេតុថ្មីដែលគាត់ស្នើឲ្យមេធាវី -- ឲ្យដើមបណ្តឹងរដ្ឋប្បវេណីនេះមកបំភ្លឺបន្ថែម។ ពេលនោះគឺមេធាវីការពារក្តីមិនបានជំទាស់ទេ។

[០៩:០៩:០០]

ដូច្នេះមូលហេតុទី២ គឺថាគេមានឱកាសគ្រប់គ្រាន់ដើម្បីចង់សួរទៅគាត់ ក្នុងពេលដែលចែកជូនឲ្យនោះ។ ហើយដែលអះអាងថា គឺបើមានអង្គហេតុថ្មី គាត់មានសំណួរថ្មីត្រូវសួរគាត់ទាក់ទងទៅនឹងអង្គហេតុថ្មី។ ទាក់ទងទៅនឹងការផ្សាយវិទ្យុ ដែលថាយើងបានជូនដំណឹងទៅគាត់។

ហើយទី៣ លោក លោកស្រីចៅក្រម គឺថាតាមឆន្ទានុសិទ្ធិរបស់ចៅក្រមក្នុងការសម្រេច ថាតើត្រូវធ្វើដូចម្តេច។ ប៉ុន្តែសំណើរបស់យើងខ្ញុំ ថាសូមឲ្យមេធាវីការពារក្តីគោរពទៅតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះកាលពីមុន ដែលថាឲ្យមេធាវីការពារក្តីសួរមុន ហើយបន្តបន្ទាប់ទៅទៀត។ នេះជាសំណើរបស់យើងខ្ញុំ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១០:០៧]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ហើយអង្គជំនុំជម្រះសម្រេចនៅតែរក្សានូវសេចក្តីសម្រេចរបស់ខ្លួនដដែល គឺផ្តល់ពេលវេលាឲ្យទៅភាគីដែលជាម្ចាស់សំណើរតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីមុនភាគីដទៃទៀតនៃរឿងក្តីនេះ។

លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនៅព្រឹកនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន។ សូមកត់សម្គាល់ដោយឡែក លោកនួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនដែលនៅពីខាងក្រោមបន្ទប់សវនាការនេះតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដោយមូលហេតុបញ្ហាសុខភាព។ រីឯដើមបណ្ដឹងរដ្ឋប្បវេណី TCCP-187 មានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ នៅថ្ងៃនេះដែរមិនមានសាក្សីបម្រុងនោះទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណីចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[០៩:១២:៣៣]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកឈ្មោះ ចៅ នី អ៊ីចឹងមែនទេ?

**លោក ចៅ នី៖**

**ឆ៖** បាទ ខ្ញុំឈ្មោះចៅ នី។

**ស៖** លោក ចៅ នី ចាំទេថាលោកត្រូវបានអង្គជំនុំជម្រះកោះអញ្ជើញលោកមកផ្ដល់សក្ខីកម្មក្នុងនាមដើមបណ្ដឹងរដ្ឋប្បវេណីកាលពីលើកមុននេះនៅថ្ងៃខែឆ្នាំណាដែរ? លោកចាំទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** លោកចៅ នី រង់ចាំបន្តិច រង់ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការដោយមានសញ្ញាភ្លើងក្រហមនៅនឹងក្បាលមីក្រូហ្វូន ឬក៏នឹងប៊ូតុងសម្រាប់ចុចនេះ លោកចាប់ផ្ដើមនិយាយ។ អាហ្នឹងទើបសំឡេងរបស់លោកចូលក្នុងប្រព័ន្ធចែកចាយសំឡេងរបស់លោក ហើយនិងជាពិសេសចូលទៅប្រព័ន្ធនៃការស្ដាប់សំឡេងរបស់អ្នកបកប្រែ។ អ្នកបកប្រែត្រូវបកប្រែភាសារបស់លោកជាពីរភាសាទៀតគឺភាសាអង់គ្លេស

និងភាសាបារាំង។

[០៩:១៣:៣៦]

**ធ៖** នៅលើកមុន ខ្ញុំឡើងសវនាការនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១២។

**ស៖** បាទ អរគុណ។ ហើយដោយសារលោកធ្លាប់បានមកផ្ដល់សក្ខីកម្មនៅទីនេះម្ដងរួចមកហើយ។ ហើយមានប្រតិចារឹក យើងបានជម្រាបជូនភាគីរួចហើយ។ ដូច្នេះយើងមិនចាំបាច់សួរនូវប្រវត្តិសាវតាររបស់លោកទៀតទេ។ ប៉ុន្តែអង្គជំនុំជម្រះក៏សូមជម្រាបរំឭកលោកផងដែរថា សិទ្ធិរបស់លោកដែលមានគឺក្នុងនាមដើមបណ្ដឹងរដ្ឋប្បវេណី គឺអាចថ្លែងរៀបរាប់ជូនដល់អង្គសវនាការអំពីស្ថានភាពនៃព្យសនកម្ម ទុក្ខវេទនា ដែលបានកើតឡើងចំពោះលោក ដែលអាចអាទ៏មានខាងការខូចខាតខាងផ្លូវចិត្ត ផ្លូវកាយ សម្ភារ ហើយព្យសនកម្មផ្ទាល់ខ្លួនដែលជាបច្ច័យខ្លួនពីបទឧក្រិដ្ឋដែលបានកើតមានពិតប្រាកដរហូតដល់ពេលបច្ចុប្បន្នដែលពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលបានចោទប្រកាន់លើជនជាប់ចោទទាំងពីររូប គឺ នួន ជា, ខៀវ សំផន ដែលប៉ះពាល់ចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នេះជានាទីចុងក្រោយនៃកិច្ចដំណើរការសវនាការនេះ។ យើងនឹងផ្ដល់ពេលវេលានេះដូចលើកមុនអ៊ីចឹង។ លោកមុនអង្គជំនុំជម្រះបានផ្ដល់ពេលវេលាហ្នឹងជូនលោកហើយ ប៉ុន្តែលោកបានប្រើប្រាស់នូវការដែលការអនុវត្តសិទ្ធិនេះ គឺលោកបានបង្កើតនូវអង្គហេតុមួយថ្មីទៀតដែលជាមិនមែនជាសេចក្ដីថ្លែងការណ៍រៀបរាប់អំពីទុក្ខសោកវេទនា និងព្យសនកម្មទេ។ អ៊ីចឹងហើយបានជានៅពេលនេះ អង្គជំនុំជម្រះនៅតែផ្ដល់សិទ្ធិឲ្យលោកនៅនាទីចុងក្រោយនៃដំណើរការផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះនេះនូវសិទ្ធិនេះដដែល។

បាទ ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុម មេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះនូវបញ្ហាទាំងឡាយដែលយល់ថាថ្មីហើយដែលត្រូវបានលើកឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ហើយក្រុមមេធាវីបានស្នើសុំអង្គជំនុំជម្រះសុំស្ដាប់បន្ថែមនូវដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក ចៅ នី។ ខ្ញុំឈ្មោះ អាកទួរ វែកគែន ខ្ញុំជាមេធាវីការពារក្ដីលោក ខៀវ សំផន។ កាលពីសវនាការថ្ងៃទី២៣ ខែវិច្ឆិកា ខ្ញុំមិនមានវត្តមាននៅទីនេះទេ។ នៅថ្ងៃនោះគឺថាលោកបានថ្លែងពីការឈឺចាប់របស់លោក។ នៅក្នុងឱកាសនោះលោកបានស្នើសុំ

លទ្ធភាពសួរសំណួរដោយផ្ទាល់ទៅកាន់លោក ខៀវ សំផន តែម្តង។ ជាដំបូងខ្ញុំចង់ប្រាប់លោកថា លោក ខៀវ សំផន នឹងឆ្លើយទៅនឹងសំណួររបស់លោក។ ក៏ប៉ុន្តែមុននឹងឲ្យគាត់ឆ្លើយខ្ញុំសូមសួរសំណួរមួយចំនួនទៅកាន់លោកអំពីអ្វីដែលលោកបានឆ្លើយកាលពីថ្ងៃទី២៣ វិច្ឆិកា (លោកថា ២២ តែតាមពិតគឺថ្ងៃ ២៣ ទេ)។ ជាដំបូងនោះ មុននឹងអាននូវអ្វីដែលលោកបានឆ្លើយនោះ ខ្ញុំសូមសួរលោកថាតើលោកមានបានទទួលឯកសារ ឬក៏មេធាវីរបស់លោកមានបានឲ្យលោកអាននូវចម្លើយរបស់លោកដែលលោកបានមកផ្តល់សក្ខីកម្មនៅថ្ងៃទី២៣ ខែវិច្ឆិកា ហ្នឹងទេ?

**លោក ចៅ នី៖**

**ឆ៖** ខ្ញុំក៏មិនទាន់បានអាន មិនទាន់បានឃើញទេ។

**ស៖** បាទ សូមអរគុណ។ ពីព្រោះថាអ្វីដែលលោកនិយាយនៅក្នុងមីក្រូនេះគឺថាត្រូវបានកត់ត្រាទុកយើងមានអត្ថបទនៃពាក្យពេចន៍របស់លោក គឺថាគ្រាន់តែវាអាចមានបញ្ហាបន្តិចបន្តួចក្នុងការបកប្រែពីព្រោះថាលោកនិយាយជាភាសាខ្មែរ ហើយខ្ញុំស្តាប់ជាភាសាបារាំង។ យើងមានប្រតិចារិក នៅថ្ងៃ ទី ២៣ ខែវិច្ឆិកា ឆ្នាំ២០១២ ដែលមានលេខកូដ E1/146.1។ លោកបាននិយាយថាលោកចង់សួរសំណួរទៅកាន់លោក ខៀវ សំផន គឺថាពូរបស់លោក ឪពុកមាររបស់លោកមានទំនាក់ទំនងជាមួយលោក ខៀវ សំផន នេះជាផ្នែកនៃចម្លើយរបស់លោក។ ហើយបន្ទាប់មកមានការជជែកគ្នារវាងភាគីពាក់ព័ន្ធទៅនឹងលទ្ធភាពដែលអាចផ្តល់ឲ្យលោកក្នុងការសួរសំណួរទៅកាន់លោក ខៀវ សំផន ដោយផ្ទាល់។ ហើយខ្ញុំសូមរំលងចំណុចនេះ។ បន្ទាប់មកអង្គជំនុំជម្រះផ្តល់វេទិកាជូនលោកវិញ។

[០៩:១៨:៥៥]

ខ្ញុំសូមដកស្រង់នូវសម្តីរបស់លោក៖ “នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺនៅថ្ងៃរំដោះ ខៀវ សំផន បានសរសេរសំបុត្រមួយដោយអញ្ជើញឪពុកមាររបស់ខ្ញុំ ចៅ សៅ សុំឲ្យគាត់ត្រឡប់មកទីក្រុងភ្នំពេញ។ ហើយខ្ញុំចង់ដឹងថាហេតុអ្វី ខៀវ សំផន -- ខ្ញុំចង់ដឹងថាតើ ខៀវ សំផន បានជួបឪពុកមាររបស់ខ្ញុំទេជាចុងក្រោយនោះ។ នេះជាសំណួរទី១របស់ខ្ញុំ។ ហើយសំណួរទី២ របស់ខ្ញុំនោះគឺថាអ្នកបើកឡានរបស់ ចៅ សៅ នៅឆ្នាំ៧៩ ខ្ញុំជួបគាត់នៅភ្នំពេញ។ គាត់បានប្រាប់ខ្ញុំថា នៅពេល ចៅ សៅ ត្រូវបានជម្លៀស នៅពេលដែលគាត់ទៅដល់ព្រែកក្តាម ទាហានពីនាក់បានឲ្យសំបុត្រមួយដែលសរសេរដោយ ខៀវ សំផន។ នៅក្នុងលិខិតនោះគឺថាមានសរសេរថា ចៅ សៅ ត្រូវមកភ្នំពេញ។ ប៉ុន្តែ ចៅ សៅ បានបដិសេធមិនព្រមមក។ គាត់ថាគាត់មកភ្នំពេញ ទាល់តែប្រជាជនទីក្រុងភ្នំពេញទាំងនុំងអាចមកចូលមក

វិញបាន។ ហើយទាហានទាំងពីរនាក់នុំងមកវិញជាលើកទី២ទៀត។ ហើយសូមឲ្យគាត់ទៅទីក្រុងភ្នំពេញ ហើយគាត់នៅតែបដិសេធដដែល។ តាំងពីថ្ងៃនោះមកលោក ចៅ សៅ ក៏បានបាត់ខ្លួន។ ខ្ញុំចង់សួរលោក ខៀវ សំផន ថាតើគាត់ ស្លាប់នៅ ឯណា? នេះជាអ្វីដែលខ្ញុំចង់ដឹង បើសិនជាខ្ញុំដឹងថាគាត់ស្លាប់នៅឯណានោះ យ៉ាងហោចណាស់ក៏ខ្ញុំអាច រកឃើញសាកសពរបស់គាត់ដើម្បីរៀបចំធ្វើពិធីបុណ្យតាមសាសនា ដើម្បីជាការគោរពវិញ្ញាណក្ខន្ធដល់គាត់។" នេះគឺជាការបញ្ចប់ការដកស្រង់។

លោកដើមបណ្ដឹងរដ្ឋប្បវេណីអ្វីដែលខ្ញុំអានអម្បាញ់មិញនេះ គឺថាវាត្រូវគ្នានឹងចម្លើយរបស់លោក ដែលលោកបានឆ្លើយកាលពីថ្ងៃទី២៣ ខែវិច្ឆិកានោះទេ?

[០៩:២១:០១]

**ឆ៖** សំណួរទាំងអស់ដែលលោកបានសួត្រអំមិញនេះ គឺខ្ញុំបាននិយាយត្រឹមត្រូវ។

**ស៖** បន្ទាប់មកខ្ញុំសួរសំណួរមួយចំនួនទៅកាន់លោក គឺសំណួរខ្លីៗទេ។ ខ្ញុំចង់សួរលោកថា តើលោកអាចប្រាប់ឈ្មោះអ្នកបើកឡាននៃឪពុកមារបស់លោកទេ?

**ឆ៖** អ្នកបើកឡានឲ្យឪពុកមារបស់ខ្ញុំហ្នឹងគឺឈ្មោះ ពូឈាន នៅកាលនោះគាត់អាយុប្រហាក់ប្រហែលជា៥០ឆ្នាំ អាយុប្រហែលជាអាយុ៥០។ គាត់ប្រហែលជារៀងចាស់ជាងឪពុកមាខ្ញុំ អ្នកបើកបរនោះ។

**ស៖** តើគាត់នៅរស់ទេសព្វថ្ងៃនេះ? ហើយបើនៅរស់គាត់ស្នាក់នៅឯណាដែរ?

**ឆ៖** នៅឆ្នាំ៧៩នោះ ខ្ញុំបានជួបគាត់ដោយចៃដន្យទេ ដោយខ្ញុំមកការគេនៅក្រោយវត្តព្រះពុទ្ធនៅភ្នំពេញនេះ។ ជួបចៃដន្យកាលណោះ ខ្ញុំមិននឹកស្មានថា តុលាការកើតឡើងថ្ងៃនេះទេ។ ខ្ញុំមិនបានសួរដេញដោលគាត់ឲ្យបានវែងឆ្ងាយទេ។ ពេលនោះ ខ្ញុំនិងគ្រួសារខ្ញុំ និងម្ដាយក្មេកខ្ញុំនៅស្ដាប់ជុំគ្នាបាទ ដើម្បីគាត់និយាយរឿងដែល ចៅ សៅ ដែលភៀសខ្លួនទៅព្រែកក្ដាម។ នៅពេលនោះ គាត់ដំណើររឿងប្រាប់ថា ពេលភៀសខ្លួនទៅដល់ព្រែកក្ដាម លោក ចៅ សៅ បានទទួលលិខិត (ដូចខ្ញុំរាបរាប់ប្រាប់ពីមុន) លិខិតទី១ អឺ! លិខិតទី២ អឺលិខិតទី១ គាត់បដិសេធថា គាត់មិនចូលក្រុងទេ លុះត្រាប្រជាពលរដ្ឋចូលក្រុង--

[០៩:២៣:២០]

**ស៖** លោក ចៅ នី ខ្ញុំយល់ច្បាស់ហើយ ក៏ប៉ុន្តែខ្ញុំសួរលោកជាក់លាក់ បើសិនជាលោកមិនឆ្លើយជាក់លាក់ទៅនឹងសំណួររបស់ខ្ញុំហ្នឹង គឺថាយើងចំណាយពេលច្រើនហើយ។ ខ្ញុំគ្រាន់តែសួរលោកថា តើគាត់នៅរស់ដែរឬទេសព្វថ្ងៃហ្នឹង ហើយបើនៅរស់គាត់រស់នៅឯណាដែរលោកដឹងទេ? នេះជាសំណួរ

របស់ខ្ញុំ។

**ឆ៖** ខ្ញុំបានជួបតែពេលនុ៎ងម្តងមក ហើយពេលនោះមិនដឹងថាគាត់នៅទីណាទៀតទេ ហើយឬដល់ពេលនេះមិនដឹងស្លាប់ ឬរស់ទេ។

**ស៖** ហើយលោកដឹងថា គាត់មកពីតំបន់ណាទេ?

**ឆ៖** អង្កាល់ណោះខ្ញុំមិនបានសួរដេញដោលគាត់ថានៅរស់តំបន់ណាទេ គ្រាន់តែថាគាត់ថា អ្នកបែកចេញពីលោក ថៅ សៅ ហ្នឹងទៅ។ ថៅ សៅ ឱ្យគាត់ទៅរកទីក្រុង -- ទៅរកគ្រួសារគាត់ទៅ។ ខ្ញុំអត់បានសួរដេញដោលទៀតទេ។

[០៩:២៤:៣៩]

**ស៖** នៅពេលឆ្នាំ១៩៧៩ ហ្នឹង លោកថា នៅពេលការនុ៎ងលោកបានជួបគាត់ហ្នឹង លោកបានជជែកគ្នាជាមួយគាត់ប្រហែលប៉ុន្មានដែរពេលនុ៎ង? រយៈពេលប៉ុន្មាន?

**ឆ៖** ពីព្រោះនៅក្នុងពិធីការគេប្រហែលជាខ្ញុំជួបរយៈពេលខ្លីដែរទេ។ ពិធីការគេវាជា*(ឮមិនច្បាស់)* អ៊ីចឹងខ្ញុំមិនបានសួរដេញដោលបានវែងឆ្ងាយទេ។ រយៈពេលប្រហែលជា១០ ទៅ១៥នាទី ប៉ុណ្ណោះទេ។

**ស៖** នៅក្នុងសក្ខីកម្មរបស់ខ្ញុំ ដែលខ្ញុំបានអានមើលឡើងវិញនោះ លោកបានបញ្ជាក់អំពីកាលបរិច្ឆេទ គឺលោកបាននិយាយថាថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ គឺនៅថ្ងៃរំដោះ។ ខៀវ សំផន បានសរសេរសំបុត្រហៅឪពុកមាខ្ញុំឲ្យមកភ្នំពេញ។ នេះជាព័ត៌មានដែលអ្នកបើកឡើងនោះប្រាប់លោកមែនទេ គឺថាសំបុត្រដែលទំនងជាលោក ខៀវ សំផន ផ្ញើជូនហ្នឹង គឺមានការបញ្ជាក់កាលបរិច្ឆេទច្បាស់លាស់ថា ថ្ងៃ១៧ មេសា ហ្នឹងមែនទេ?

**ឆ៖** មិនមែនថ្ងៃ១៧ មេសា ក្រោយហ្នឹងប្រហែលរយៈពេល៣ថ្ងៃ ទើបគាត់ទៅដល់ព្រែកក្តាម ទើបសំបុត្រហ្នឹងទៅដល់លោកនៅព្រែកក្តាម លោក ថៅ សៅ នៅព្រែកក្តាម។ មិនមែនថ្ងៃ១៧ មេសា ហ្នឹងតែម្តងទេ។

[០៩:២៦:២៤]

**ស៖** ហេតុអ្វីបានជានៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២ នៅចំពោះមុខអង្គជំនុំជម្រះនេះ លោកឆ្លើយលោកបានផ្តល់កាលបរិច្ឆេទនុ៎ង គឺថាថ្ងៃ១៧ មេសា នោះ?

**ឆ៖** មិនមែនៗថ្ងៃ១៧ទេ គឺក្រោយមករយៈពេល៣ថ្ងៃ ពីព្រោះ ថៅ សៅ ភៀសខ្លួនទៅដល់ព្រែកក្តាមហើយ។ ចេញពីទួលគោកទៅព្រែកក្តាមហើយ។ ផ្ទះគាត់នៅទួលគោក ចេញពីទួលគោកទៅ

ដល់ព្រែកក្ដាមហ្នឹងហើយ។ មិនមែនថ្ងៃ១៧ ទេ។

**ស៖** ខ្ញុំយល់ហើយនូវចម្លើយរបស់លោកនៅពេលនេះ ក៏ប៉ុន្តែចម្លើយលោកមុននោះ កាលថ្ងៃទី ២៣ វិច្ឆិកា ហ្នឹងវាខុសគ្នា។ ហេតុអី អ៊ីចឹងខ្ញុំចង់ដឹងថា ម៉េចបានជានៅថ្ងៃទី២៣ វិច្ឆិកា លោកឆ្លើយថា ១៧មេសា ក៏ប៉ុន្តែនៅថ្ងៃនេះលោកថា ប៉ុន្មានថ្ងៃក្រោមមកទេបានមានលិខិតនោះ។ លោកច្រឡំ ឬក៏យ៉ាង ម៉េច ឬក៏លោកចង់កែតម្រូវចម្លើយរបស់លោកកាលពីឆ្នាំមុននោះ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[០៩:២៧:៤៧]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោក លោកស្រីចៅក្រម យើងខ្ញុំចង់ឲ្យបំភ្លឺ។ តាមខ្ញុំអានប្រតិចារឹកនោះថា ដើមបណ្ដឹងរដ្ឋប្បវេណីចង្អុលបង្ហាញថា គាត់គិតថាលិខិតនោះត្រូវបានសរសេរនៅថ្ងៃទី១៧ មេសា មិនមែនមានន័យថា លិខិតនោះទៅដល់លោក ចៅ សៅ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទេ។ ដូច្នេះប្រហែលជាគាត់ យោងទៅរកកាលបរិច្ឆេទដែលចុះលើលិខិតដែលគេបានសរសេរទេ មិនមែនថាលិខិតនោះទៅដល់ដៃលោក ចៅ សៅ នៅថ្ងៃនោះទេបាទ។

**លោក អាកឡូវ វែកគែន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាកឡូវ វែកគែន៖**

**ស៖** បាទ នេះជាការយល់របស់ខ្ញុំពីចម្លើយរបស់លោកកាលពីថ្ងៃទី២៣ វិច្ឆិកា។ ខ្ញុំអានម្ដង ហើយម្ដងទៀត បីដងហើយ ដើម្បីព្យាយាមឲ្យយល់នូវចម្លើយរបស់លោក។ លោកបានឆ្លើយថា ថ្ងៃ១៧ មេសា ឆ្នាំ៧៥ ថ្ងៃរំដោះទីក្រុងភ្នំពេញ លោក ខៀវ សំផន បានចារលិខិតមួយទៅអញ្ជើញអ៊ំរបស់ខ្ញុំ ឈ្មោះ ចៅ សៅ ឲ្យចូលទីក្រុងភ្នំពេញវិញ។ ដូច្នេះ ខ្ញុំចង់ដឹងថានៅពេលដែលលោកជជែកគ្នាជាមួយនឹង អ្នកបើកឡាននោះ គឺគាត់ទេជាអ្នកប្រាប់លោកថាសំបុត្រនោះទំនងជាសរសេរនៅថ្ងៃរំដោះ គឺមានន័យ ថានៅថ្ងៃទី១៧ មេសា គឺថាកាលបរិច្ឆេទហ្នឹង គឺអ្នកបើកឡើងហ្នឹងជាអ្នកប្រាប់លោកទេ មែនទេ?

[០៩:២៨:២៩]

**ឆ៖** នៅពេលនោះ គាត់និយាយអ៊ីចឹងមែន ក៏ប៉ុន្តែបើសំបុត្រដែលគាត់និយាយថាបានទទួលនោះ គឺក្រោយៗហ្នឹង៣ថ្ងៃទេ។ ក្នុងកាលបរិច្ឆេទ ប្រហែលជាថ្ងៃ១៧ មេសា ពីព្រោះនៅថ្ងៃ១៧ មេសា ហ្នឹង វាវិទ្យុជាតិបានប្រកាសរក ចៅ សៅ, ឡុង បូរ៉េត, ចេង ហេង, សិរិមតៈ។ អ៊ីចឹងនៅក្នុងហ្នឹង មានប្រកាសរក ចៅ សៅ ឲ្យចូលក្រុងវិញអ៊ីចឹងដែរ។ ក្រោយមកបានគាត់បានទទួលសំបុត្រនោះនៅក្រោយពីថ្ងៃនោះមកទេ។

**ស៖** ហើយចំពោះលោកផ្ទាល់ហ្នឹង នៅសម័យនោះលោកស្តាប់ឮដោយត្រចៀកលោកផ្ទាល់ទេ អំពីការផ្សាយតាមវិទ្យុហ្នឹង?

**ឆ៖** ពីព្រោះពេលរំដោះថ្ងៃ១៧ មេសា ភ្លាមៗខ្ញុំនៅមានវិទ្យុស្តាប់ទេ ស្តាប់ផ្ទាល់បាទ នៅស្តាប់ផ្ទាល់ ហើយនិងម្តាយក្មេកខ្ញុំក៏គាត់ស្តាប់ឮដែរ។ ហេតុដូច្នេះហើយខ្ញុំស្តាប់ផ្ទាល់ក៏ឮ ម្តាយក្មេកខ្ញុំនិយាយប្រាប់តាមក្រោយមកក៏ឮ។ អ៊ីចឹងវាត្រូវគ្នានឹងខ្ញុំស្តាប់ពេលថ្ងៃ១៧ មេសា ក្រោយមកគឺប្រកាសរកឈ្មោះទាំងអ្នកប៉ុន្មាននាក់នេះ។

[០៩:៣១:១២]

**ស៖** តើលោកអាចបញ្ជាក់បានទេថា កាលពីសម័យនុំងឪពុកមារបស់លោកហ្នឹងធ្វើការអ្វីដែរ?

**ឆ៖** ឪពុកមាខ្ញុំគាត់ធ្វើការនៅធនាគារជាតិ បើកាលនោះគេហៅថាឥណទានជាតិ។

**ស៖** ពេលចុងក្រោយដែលលោកបានឃើញគាត់នោះ នៅពេលណាដែរ?

**ឆ៖** សូមទោសលោកមេធាវី តើពេលណា? ពេលចុងក្រោយណា? ពេលនៅឆ្នាំ៧៥ ឬមួយចុងក្រោយណាខ្ញុំមិនយល់អំពីលោកមេធាវីសួរខ្ញុំ។

**ស៖** បាទ គឺមិនមែនឥឡូវនេះទេ គឺពីមុននោះ ចង់បានសេចក្តីថាពេលសម័យនុំង គឺថាជាថ្ងៃចុងក្រោយបំផុតដែលលោកជួបគាត់នុំង គឺថានៅថ្ងៃណាដែរ?

**ឆ៖** ពីព្រោះដែលកាលនោះខ្ញុំនៅតូចដែរ ខ្ញុំនៅអូឡាំពិកនោះទេ។ អ៊ីចឹងឪពុកមាខ្ញុំគាត់នៅទួលគោក មិនសូវបានជួបគ្នាញឹកញាប់ទេ។ ពីព្រោះខ្ញុំក្មេងៗ ហើយគាត់ជាអ្នកការងារធំដុំ យើងមិនសូវបានជួបគាត់ញឹកញាប់ទេ។ ហើយចុងក្រោយបង្អស់នេះ ដែលបានឃើញគាត់នោះ គាត់ដឹកអីវ៉ាន់គាត់ពេលជិតរំដោះនេះយកទៅទុកនៅផ្ទះខ្ញុំនៅជាមួយបងខ្ញុំនៅទួលគោកតែប៉ុណ្ណោះទេ។ អីវ៉ាន់ផ្ទះប៉ុន្មានដែលនៅក្នុងទួលគោក គាត់ថាគាត់មិនទុកនៅនេះទេ គាត់ដឹកយកទៅទុកនៅផ្ទះខ្ញុំនៅផ្ទះដែលខ្ញុំជួលលោក ចៅ បាន នៅទួលគោក -- អំ! អូឡាំពិក។ ជួបនៅពេលចុងក្រោយ គឺមុនថ្ងៃរំដោះប្រហែលជា៣ថ្ងៃ។

[០៩:៣៣:៤៥]

**ស៖** បាទ សូមអរគុណ។ ចុះចំពោះលិខិតដែលអ្នកបើកបរនិយាយប្រាប់លោកនុ៎ង គឺថាជាលើកទី១ គឺថាដែលលោកបានដឹងថាមានវត្តមានលិខិតនោះនុ៎ងមែនទេ នៅកាលពីឆ្នាំ៧៩នុ៎ង?

**ឆ៖** សូមទោសលោកមេធាវី លោកសួរលិខិត៧៩ ខ្ញុំអត់មាន៧៩ទេ។ លិខិតដែលទទួលបាននោះគឺនៅក្នុងសម័យរំដោះ គឺនៅក្រោយថ្ងៃ១៧ មេសា ទេ។ ៧៩ អត់មានលិខិតណាទេ។ ខ្ញុំបានទទួលដំណឹង លិខិតពីអ្នកបើកបររបស់ ចៅ សៅ នៅឆ្នាំ៧៩ មិនមែនលិខិតបានទទួលនៅក្នុងឆ្នាំ៧៩ទេ។

**ស៖** បាទ ជាអ៊ីចឹងហើយលោក។ លិខិតដែលលោកបានឆ្លើយប្រាប់យើថា អ៊ំរបស់លោកជាអ្នកទទួល ហើយគឺថាបានន័យថាគាត់ទទួលប៉ុន្មានថ្ងៃក្រោយពេលរំដោះនោះ។ ចំពោះលោកខ្លួនឯងផ្ទាល់នោះ លោកបានឃើញទេ ឬក៏លោកគ្រាន់តែបានឮតាមរយៈអតីតអ្នកបើកឡានរបស់អ៊ំលោកទេ?

**ឆ៖** នៅថ្ងៃដែលគាត់បានទទួលនោះ ខ្ញុំមិនមែននៅជាមួយគាត់ទេ។ ពីព្រោះខ្ញុំ កាលនោះខ្ញុំបែកចេញទៅផ្លូវជាតិលេខ២ គាត់ទៅផ្លូវជាតិ៥ឯណោះ ធ្វើម៉េចខ្ញុំបានដឹងនូវលិខិតនោះ។ ក៏ប៉ុន្តែដល់៧៩ដែលខ្ញុំបានមកការគេនៅក្រោយវត្តព្រះពុទ្ធនេះ ខ្ញុំបានទទួលដំណឹងនេះពីអ្នកបើកបររបស់ ចៅ សៅ នេះទេ។ ត្រង់លិខិតនោះមានអត្ថន័យយ៉ាងណា លោកខៀវ សំផន សរសេរយ៉ាងណាទៅឲ្យលោក ចៅ សៅនោះក៏ខ្ញុំមិនបានដឹងថាយ៉ាងណាដែរ។ កាលដែលលិខិតនោះ -- ទី១, ដល់ទី២ អ៊ីចឹង ដល់លិខិតទី២គាត់ឲ្យតែកុងឡាន គាត់ទៅរកគ្រួសារទៅ។ តាំងពីនោះមក គាត់ក៏លែងបានទទួលដំណឹងពី ចៅ សៅ ហើយ ចៅ សៅ ក៏បាត់ដំណឹងពីនោះរហូតដល់បច្ចុប្បន្នមិនដឹងថា ចៅ សៅ ស្លាប់ឬរស់នៅទីណាដែរ។

[០៩:៣៦:៣៣]

**ស៖** ដូច្នេះអម្បាញ់មិញនេះ លោកនិយាយថាមានលិខិតពីរ អ៊ីចឹងមែនទេ? ខ្ញុំយល់អ៊ីចឹងត្រូវទេ?

**ឆ៖** បាទ លិខិតនោះអ្នកបើកបរនិយាយប្រាប់ខ្ញុំ គឺមានពីរដង។ មួយម្តងគាត់មិនទទួលថាគាត់មិនចូលក្រុងវិញទេ។ ដល់ម្តងក្រោយទៀត នៅក្នុងអត្ថន័យនោះមិនដឹងថាម៉េច គាត់ឲ្យអ្នកបើកបរនោះត្រឡប់ទៅរកគ្រួសារវិញចុះ។ ពីព្រោះប្រហែលជាគាត់យល់ថា ផែនការអត់ស្រួលឬយ៉ាងណា ខ្ញុំក៏អត់ដឹងដែរ។ ប៉ុន្តែគាត់និយាយប្រាប់ខ្ញុំថា "ពេលនោះលោកឲ្យខ្ញុំទៅរកគ្រួសារវិញចុះ" នេះជាពាក្យរបស់អ្នកបើកបរ ពូឈៀង និយាយប្រាប់ខ្ញុំ និងម្តាយមីងខ្ញុំ។

**ស៖** នៅពេលដែលលោកជជែកគ្នា១៥នាទី ជាមួយអ្នកបើកឡាននៅឆ្នាំ៧៩នោះ គាត់មានបានប្រាប់លោកទេថាអ្នកណាជាអ្នកចុះហត្ថលេខាលើសំបុត្រទី២ ហើយសំបុត្រទី២នោះត្រូវបានសរសេរ

នៅថ្ងៃណាខែណា ឆ្នាំណាដែរ?

**ឆ៖** អាហ្នឹងខ្ញុំមិនបានសួរដេញដោលគាត់ទេ។ គ្រាន់តែគាត់និយាយប្រាប់ប៉ុណ្ណឹង យើងគ្រាន់តែដឹងដំណឹងគាត់បាត់ខ្លួនតាំងគាត់ចាកចេញពីលោក។ កាលណោះ គាត់ហៅតែលោកៗទេ ពីព្រោះគាត់បើកតែកុងឡានឲ្យ ថៅ សៅ ហ្នឹងគាត់ហៅតែលោកទេ។ ដែលពេលលោកដេញឲ្យខ្ញុំទៅរកគ្រួសារនោះ គឺខ្ញុំបាត់ដំណឹង មិនដឹងថាលិខិតនោះចុះថ្ងៃណា គឺអត់ដឹងទេ។ ក៏ប៉ុន្តែនៅក្រោយរំលងពីលិខិតទី១នោះ ប្រហែលជារយៈ២ថ្ងៃ។

[០៩:៣៨:៣៧]

**លោក អាកទូរ វែកគែន៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។ ក៏ប៉ុន្តែលោក ខៀវ សំផន ចង់និយាយជាមួយដើមបណ្ដឹងរដ្ឋប្បវេណី។ តើលោកប្រធានអនុញ្ញាតដែរឬទេ?

**ប្រធានអង្គជំនុំ៖**

លោកអាចសួរនាំបាន ប៉ុន្តែលោកសួរតាមរយៈអង្គជំនុំជម្រះ តាមរយៈប្រធានអង្គជំនុំជម្រះ។ លោកមិនអាចនិយាយផ្ទាល់ជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណីបានទេ។

**លោក គង់ សំអុន៖**

លោកប្រធាន ខ្ញុំសូមកែតម្រូវបន្តិច។ អំមិញការពិតទៅ មិនមែនលោក ខៀវ សំផន ចង់និយាយទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណីទេ។ ក៏ប៉ុន្តែសំណួរដែលដើមបណ្ដឹងរដ្ឋប្បវេណីបានសួរតាមរយៈលោកប្រធានពីពេលនោះ គាត់មិនទាន់បានឆ្លើយ ហើយគាត់មិនបានឆ្លើយពីមុន។ ឥឡូវគាត់ចង់ឆ្លើយទៅនឹងសំណួរនោះ។ ដូច្នេះឆ្លើយគឺតាមរយៈលោកប្រធានដែរបាទ។ សូមកត់សម្គាល់តែប៉ុណ្ណេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោកដើមបណ្ដឹងរដ្ឋប្បវេណីនៅតែចង់សួរ តាំងសំណួរទៅចំពោះ ខៀវ សំផន ដែរឬទេ? សំណួរដែលលោកបានមានបំណងបានតាំងសំណួរលោកមុន ហើយមានបញ្ហាបច្ចេកទេសនៃដំណើរការហើយមានបញ្ហាមិនអាចប្រព្រឹត្តបានចប់ចុងចប់ដើមកាលណោះ។ ហើយនាពេលនេះ តើលោកមានបំណងចង់តាំងសំណួរនេះទៅជនជាប់ចោទ ខៀវ សំផន ដែរឬទេ?

**លោក ចៅ នី៖**

នៅឱកាសនេះ ខ្ញុំសូមគោរពលោកប្រធាន។ អីចឹងខ្ញុំសូមបន្ថែមខ្លះៗទៀតទៅលើសំណួរ ចាស់។

**ប្រធានអង្គជំនុំ៖**

លោកចាប់ផ្តើមតាំងសំណួរទាំងអស់ហ្នឹងឡើងវិញ លោកសួរសំណួរមួយម្តងដើម្បីយើង បញ្ជូនសំណួរទៅឲ្យគាត់ឆ្លើយ។ សំណួរដែលលោកសួរត្រូវចាប់ផ្តើមសួរឡើងវិញគឺ ខៀវ សំផន ទំនងជាត្រៀមខ្លួនរួចហើយក្នុងការឆ្លើយតបទៅនឹងសំណួរដែលលោកមានបំណងសួរនេះ។

[០៩:៤០:៥៥]

**លោក ចៅ នី៖**

បើអ៊ីចឹងខ្ញុំសូមសួរសំណួរដែលខ្ញុំសួរពីមុននោះឡើងវិញ ហើយនិងបន្ថែមខ្លះទៅលើសំណួរចាស់។ ខ្ញុំចង់សួរទៅលោកអ៊ំ ខៀវ សំផន ថា ពេលដែលលិខិតលោកផ្ញើទៅឲ្យលោកឪពុកមារបស់ខ្ញុំ ចៅ សៅ នោះតើអត្ថន័យក្នុងលិខិតនោះដូចម្តេចខ្លះ? ទី១ គាត់បដិសេធមិនព្រមចូលក្រុងវិញទេលុះត្រាប្រជាពលរដ្ឋចូល។ ទី២ ហេតុអីបានតែលោក ចៅ សៅ ឪពុកមារបស់ខ្ញុំនេះ គាត់ឲ្យអ្នកបើកបរឡានគាត់នោះទៅរកគ្រួសារវិញ? មកពីក្នុងអត្ថន័យលិខិតនោះដូចម្តេចខ្លះបានតែគាត់មិនឲ្យតៃកុងឡាននេះនៅពាក់ព័ន្ធជាមួយគាត់? តាំងពីសំបុត្រទី២នោះគាត់បានទទួលហើយ ចៅ សៅ ក៏បាត់ខ្លួនរហូតដល់បច្ចុប្បន្ន។ បើលោកអ៊ំ ខៀវ សំផន ដឹងថាគាត់ស្លាប់នៅកន្លែងណា? ឬគាត់ស្លាប់នឹងអត់បាយ ឬជំងឺ ឬមួយគេធ្វើឃាតកម្មទៅលើគាត់នៅកន្លែងណា? ហើយគាត់ជម្លៀសហ្នឹងទៅទីណា? សូមអ៊ំប្រាប់ខ្ញុំផង ដើម្បីខ្ញុំយកធាតុគាត់ធ្វើបុណ្យតាមប្រពៃណីរបស់ខ្មែរ។ អ៊ំក៏សញ្ជាតិខ្មែរដែរ អ៊ំប្រហែលជាដឹងពីរឿងនេះច្បាស់ណាស់។ ខ្មែរយើង អ្វីមួយយើងត្រូវតែរំឭកពីគុណរបស់គាត់។ ពីព្រោះ ចៅ សៅ គឺគាត់--

**ប្រធានអង្គជំនុំ៖**

បាន ហើយលោកសួរ លោកអត្ថាធិប្បាយថែមទៀតអ្នកស្តាប់សំណួរហ្នឹងម៉េចនឹងចងចាំទៅ។ បាទ អង្គជំនុំជម្រះសូមបញ្ជូននូវសំណួរនេះទៅលោក ខៀវ សំផន ដើម្បីឆ្លើយតបព្រោះមិញលោកបានបង្ហាញជំហាពីការឆ្លើយតបទៅនឹងសំណួរដែលនឹងសួរដោយដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

សូមអញ្ជើញលោក ខៀវ សំផន!

[០៩:៤៣:០០]

**លោក ខៀវ សំផន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអស់លោក លោកស្រីចៅក្រម។ សូមគោរពអង្គសវនាការទាំងមូល។ (សុំទោស) សូមគោរពបងប្អូនរួមជាតិទាំងអស់។ ជម្រាបសួរលោក ចៅ នី!

ខ្ញុំសូមជម្រាបលោកថា ខ្ញុំធ្លាប់ស្គាល់លោក ថៅ សៅ។ កាលក្នុងអំឡុងឆ្នាំ៦០គាត់បានធ្វើជាប្រធានធនាគារមួយហៅថា "ធនាគារឥណទានជាតិ"។ ហើយខ្ញុំយល់នូវទឹកចិត្តរបស់លោក ទុក្ខសោកសង្រេងរបស់លោក និងក្រុមគ្រួសាររបស់លោក ខិតខំស្វែងរកដំណឹងពីលោកអ៊ំរបស់លោក ពីជោគវាសនារបស់អ៊ំរបស់លោក ហើយបើប្រសិនជាលោកបានចាកចែកឋានទៅហើយ នឹងយកសពរបស់លោកមកធ្វើបុណ្យតាមគន្លងប្រពៃណីព្រះពុទ្ធសាសនារបស់យើង។ ប៉ុន្តែជាការគួរឲ្យសោកស្តាយ ខ្ញុំមិនមានដំណឹងអ្វីទាល់តែសោះអំពីជោគវាសនារបស់អ៊ំរបស់លោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ឯពាក្យថាមានអ្នកណាអាចជម្រាបលោកថា ខ្ញុំបានសរសេរសំបុត្រទៅអ៊ំរបស់លោកនោះ មិនមែនជាការពិតទេ។ ខ្ញុំគ្មានទាហានណានៅក្រោមបង្គាប់របស់ខ្ញុំដើម្បីខ្ញុំផ្ញើសំបុត្រទៅតាមគេនោះទេ។ ហើយម្យ៉ាងទៀតដូចលោកជ្រាបហើយ ខ្ញុំត្រូវបង្ខំចិត្តរត់គេចខ្លួនចេញពីភ្នំពេញ ចោលម្តាយរបស់ខ្ញុំដែលគាត់ចាស់ជរា គាត់នៅជាមួយខ្ញុំ ធ្លាប់នៅជាមួយ ខ្ញុំចោលប្អូនៗដែលធ្លាប់តែពឹងពាក់ខ្ញុំតាំងពីឆ្នាំ១៩៦៧មក។ ហើយតាំងពីពេលនោះមកអ៊ំរបស់លោក ហើយនិងខ្ញុំក៏មិនដែលបានជួបមុខគ្នាម្តងណាទាល់តែសោះ។ សរុបមកខ្ញុំមិនមានមធ្យោបាយអីនឹងផ្ញើសំបុត្រទៅអ៊ំរបស់លោកទាល់តែសោះ។

[០៩:៤៧:២១]

ម្យ៉ាងទៀត ខ្ញុំមិនដែលមានគំនិតអីនឹកភ្នកទៅរកអ៊ំរបស់លោក អញ្ជើញអ៊ំរបស់លោកឲ្យមកភ្នំពេញនោះក៏អត់សោះ អត់ទាល់តែសោះ។ ហ្នឹងខ្ញុំសូមជម្រាបលោកដូច្នេះ។ ថ្ងៃនេះខ្ញុំដោយសារមនោសញ្ចេតនារបស់ខ្ញុំគោរព និងយល់ច្បាស់នៅសោកសង្រេងរបស់លោកនិងក្រុមគ្រួសាររបស់លោកនឹករឮកដល់អ៊ំរបស់លោក នេះហើយដែលខ្ញុំត្រូវការជួបលោកដោយផ្ទាល់ដើម្បីជម្រាបលោកដោយផ្ទាល់មាត់ ដោយអស់ពីថ្លើមពីចិត្តរបស់ខ្ញុំ ដើម្បីយើងទាំងពីរនាក់ជ្រះស្រឡះជាមួយគ្នា។ ខ្ញុំស្តាយណាស់ដោយខ្ញុំគ្មានមធ្យោបាយដើម្បីរួមចំណែកបំពេញសំណូមពររបស់លោក។ ខ្ញុំសង្ឃឹមថាលោកយល់អធ្យាស្រ័យដល់ខ្ញុំ។ សូមអស់។ អរគុណបាទ។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តមានបញ្ហាអីទៀតទេ លោក ថៅ សៅ? អឺ! ថៅ នី?

**លោក ថៅ នី៖**

សូមជម្រាបលោកចៅក្រម ខ្ញុំនៅតែមិនអស់ចិត្ត ពីព្រោះគាត់លោក អ៊ំ ខៀវ សំផន ហើយនិង ថៅ សៅ គាត់ជិតស្និទ្ធនឹងគ្នាណាស់។ សូម្បីតែទៅហូបបាយនៅផ្ទះ ថៅ សៅ ក៏គាត់ទៅហូបបាយផ្ទះ

ចៅ សៅ នៅទួលគោកនុ៎ងដែរ។ អ៊ីចឹងបានជាខ្ញុំនៅសោកស្ដាយទោះបីយ៉ាងណាក៏ដោយសូមឲ្យលោកអ៊ំប្រាប់ឲ្យត្រង់នឹងខ្ញុំមក បើអ៊ំបាច់លាក់លៀមទេ ខ្ញុំមិនមែនចោទប្រកាន់ថាអ៊ំជាអ្នកសម្លាប់គាត់ទេ។

[០៩:៥០:០៤]

**ប្រធានអង្គជំនុំ៖**

អម្បាញ់មិញនេះ ខាងមេធាវីការពារក្ដី ខៀវ សំផន បានសួរលោកច្បាស់លាស់ណាស់អំពីប្រភពព័ត៌មានទាំងឡាយដែលនាំឲ្យលោកគិតថា ខៀវ សំផន ជាអ្នកបញ្ជូនលិខិតតាមរយៈកងទ័ពទៅឲ្យ ចៅ សៅ។ ប៉ុន្តែប្រភពព័ត៌មាននោះ ការសួរដេញដោលទៅ លោកមិនមានប្រភពព័ត៌មានអីឲ្យបានរឹងមាំទេ។ ហើយគាត់បានបញ្ជាក់ អ៊ីចឹងហើយបានជាបានបញ្ជាក់ពីសួរច្រើនលើកច្រើនសាអំពីបញ្ហាពាកព័ន្ធជាមួយនឹងទំនាក់ទំនងនៃលិខិតនេះរួចហើយ។

បាទ ជាបន្តអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីនូវផ្នែកអង្គហេតុថ្មីដែលដាក់ដេញដោលនាពេលនេះ ប្រសិនបើមានបំណងក្នុងការសួរបន្ថែម។ សូមអញ្ជើញ!

[០៩:៥១:២៣]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងសួរសំណួរដោយសង្ខេបតាមបន្ទាប់ពីមេធាវីការពារ។

លោក ចៅ នី ខ្ញុំសូមអរគុណដែលលោកបានអញ្ជើញត្រឡប់មកវិញ ដែលថាលោកមិនមានអារម្មណ៍ធូរស្រាលទេក្នុងការពិភាក្សាអំពីបញ្ហានេះ។ ខ្ញុំសូមត្រឡប់ទៅរកការពិភាក្សាដែលលោកមានជាមួយអ្នកបើកបររបស់លោក ចៅ សៅ អំពីលិខិត អំពីសំបុត្រនោះ។

**ស៖** ខ្ញុំសូមសួរលោកសំណួរទី១ ថាតើគាត់បានប្រាប់លោកថាគាត់បានឃើញសំបុត្រនោះដែរឬទេ? ដោយផ្ទាល់របស់អ្នកបើកបរនោះ?

[០៩:៥២:១០]

**លោក ចៅ នី៖**

**ឆ៖** សូមជម្រាបលោកសហព្រះរាជអាជ្ញា កាលនោះគាត់និយាយប្រាប់ខ្ញុំ គាត់គ្រាន់តែ -- ចៅ សៅ និយាយប្រាប់បន្តមកគាត់វិញទេ គាត់ថាលិខិតមានមែន ក៏ប៉ុន្តែក្នុងលិខិតមិនដឹងថាអត្ថន័យយ៉ាងណាគឺអត់ដឹងទេ។ នេះសំបុត្រទី១។ មានសំបុត្រទៅដល់គាត់ពីរមែន ក៏ប៉ុន្តែដល់សំបុត្រទី២នោះ គឺ ចៅ

សៅ ដេញឲ្យគាត់ទៅរកគ្រួសារទៅ ដល់ផុតពីនោះមក គាត់អត់បានទំនាក់ទំនងអីជាមួយលោក ចៅ សៅ ទៀតទេ ដេញអ្នកបើកបរនោះ។

**ស៖** ដើម្បីឲ្យប្រាកដថា យើងខ្ញុំយល់នោះ គឺលោក ចៅ សៅ បានប្រាប់ ឈាន ជាអ្នកបើកបររបស់គាត់ថាលោក ចៅ សៅ បានទទួលសំបុត្រហ្នឹងពីលោក ខៀវ សំផន។ តើអ្នកបើកបរនោះ បានប្រាប់លោកបែបនោះទេ?

[០៩:៥៣:១៥]

**ឆ៖** គាត់បាននិយាយ -- បានប្រាប់ពិតមែន។

**ស៖** តាមដែលខ្ញុំយល់ តើត្រូវដែរឬទេ? ខ្ញុំសួរខុសពីនេះវិញ។ តើ ចៅ សៅ បានប្រាប់រឿងនេះទៅ ឈាន ជាអ្នកបើកបរនោះនៅពេលណាដែរ?

**ឆ៖** លោកសហព្រះរាជអាជ្ញា នេះសំបុត្រទី១គាត់ប្រាប់ គ្រាន់តែទទួលបានហើយភ្លាម ទាហានដែលពីរនាក់ត្រឡប់ទៅវិញ គឺគាត់និយាយប្រាប់ថា គាត់មិនត្រឡប់ចូលក្រុងវិញទេ។ អានេះសំបុត្រទី១។ ដែលសំបុត្រទី២ ក្រោយរំលងប្រហែលជា២ថ្ងៃក្រោយមកទៀត គាត់មិនបាននិយាយប្រាប់អីទាំងអស់ គ្រាន់តែលោក ចៅ សៅ ប្រាប់គាត់ឲ្យ "ឈាន ឯងត្រឡប់ទៅរកគ្រួសារវិញចុះ"។

**ស៖** ខ្ញុំយល់ហើយ សំណួររបស់ខ្ញុំគឺខ្ញុំចង់ដឹងពីសុន្ទនាររវាង ចៅ សៅ ហើយនិង ឈាន ជាការសុន្ទនាដំបូង ទាក់ទងទៅនឹងសំបុត្រទី១។ តើលោកបានដឹងឬទេថា តើការសុន្ទនារនោះ កើតឡើងនៅពេលណា? ៣ថ្ងៃក្រោយពីថ្ងៃរំដោះថ្ងៃទី១៧ មេសា ឬក៏ប៉ុន្មានថ្ងៃតាមដែលអ្នកបើកបរនោះប្រាប់លោក?

[០៩:៥៤:៤៣]

**ឆ៖** ក្រោយពីថ្ងៃ១៧មេសា ប្រហែលជា២ ឬ៣ថ្ងៃ ដែលគាត់និយាយ។ ដែលគាត់បានទទួលដំណឹងនេះក្រោយ២ ឬ៣ថ្ងៃ មិនមែននៅថ្ងៃ១៧ មេសា ទេ។

**ស៖** តើ ឈាន បានប្រាប់លោកដែរឬទេថា ក្រោយពីសំបុត្រទី១ នោះរយៈពេលប៉ុនណាដែលថាគាត់បានទទួលសំបុត្រទី២ ដែលលោក ចៅ សៅ បានទទួលសំបុត្រទី២នោះបាទ?

**ឆ៖** ក្រោយប្រហែលជាពីរបីថ្ងៃក្រោយមកទៀតបានសំបុត្រទី២។ សំបុត្រទី២ នេះមកគឺគាត់ ចៅ សៅ នេះគាត់អត់បាននិយាយប្រាប់អីទៅ ឈាន ទេ គ្រាន់តែថាឯងទៅរកគ្រួសារឯងចុះ។ គាត់មិនបាននិយាយថាក្នុងអត្ថន័យសំបុត្រនោះថាម៉េចទៅលើគាត់ ហើយឬមួយគេចង់ធ្វើម៉េចលើ ចៅ សៅ នោះគាត់ក៏អត់ដឹងដែរ គាត់គ្រាន់តែប្រាប់ថាឲ្យ ឈាន ហ្នឹងត្រឡប់ទៅគ្រួសារវិញចុះ។ ហើយតាំងពី

នោះមក ឈាន និងគាត់ឈប់ជួបគ្នារហូត។

[០៩:៥៦:០៨]

**ស៖** សូមអភ័យទោសខ្ញុំទទួចចង់ដឹងពីលោក។ បើសិនជាលោកមិនដឹងសូមលោកឆ្លើយថាមិនដឹង។ ឥឡូវសំបុត្រទី១ បាទគឺថាមកដល់គាត់ពីរបីថ្ងៃក្រោយពីរំដោះ។ រីឯសំបុត្រទី២ តើលោកដឹងទេថាសំបុត្រទី២នោះមកដល់លោកថៅ សៅ ហ្នឹងគឺរយៈប៉ុន្មានថ្ងៃ ឬក៏ក្នុងរយៈពេលក្រោយពីសំបុត្រទី១នោះ?

**ឆ៖** នេះខ្ញុំគ្រាន់តែខ្ញុំនិយាយតាមដែលពូ ឈាន និយាយប្រាប់ខ្ញុំទេ ក្រោយពីសំបុត្រទី១ពីរថ្ងៃ។

**ស៖** សូមអរគុណ។ តើ ថៅ សៅ បានប្រាប់ ឈាន មានអ្វីសរសេរនៅក្នុងសំបុត្រទី២នោះទេ ខ្លឹមសារដូចម្ដេចដែរឬទេ?

**ឆ៖** លោកសហព្រះរាជអាជ្ញា លោកសួរខ្ញុំថាពីសំបុត្រទី១ ឬសំបុត្រទី២?

**ស៖** បាទ ខ្ញុំសួរលោកពីសំបុត្រទី២ ថាតើលោក ថៅ សៅ បានប្រាប់ពីខ្លឹមសារនៃសំបុត្រទី២ នេះទៅដល់ ឈាន ជាអ្នកបើកបររបស់គាត់ទេ តាមដែល ឈាន ប្រាប់លោកនោះ?

[០៩:៥៧:៣៨]

**ឆ៖** ពេលដែលទទួលសំបុត្រទី២នោះគឺ ថៅ សៅ អត់បាននិយាយអ្វីប្រាប់ ឈាន ទេ។ ក្រោយមកគឺគាត់ឲ្យ ពូឈាន ហ្នឹងទៅរកគ្រួសារវិញចុះ មិនបាច់នៅជាមួយគាត់ទេ។ គាត់គ្រាន់តែដេញឲ្យពូ ឈាន ទៅរកគ្រួសារទេ គាត់មិនបាននិយាយអ្វីពីសំបុត្រទី២នោះទេ។

**ស៖** ខ្ញុំចង់ឲ្យលោកបំភ្លឺចំណុចចុងក្រោយ នៅក្នុងផ្នែកមួយដែលមេធាវីការពារក្ដី ខៀវ សំផន បានអានជូនលោកស្ដាប់នោះ។ នៅផ្នែកមួយលោកបាននិយាយថា សំបុត្រទី២១ ក៏ជាការអញ្ជើញឲ្យអ៊ំរបស់លោកមកភ្នំពេញនោះផងដែរ។ តើលោកនៅចាំខ្លឹមសារអ្វីច្បាស់ដែរឬទេបាទ?

**លោក អាកទ្បូ វែកគែន៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាល់ទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីការពារក្ដីលោក ខៀវ សំផន!

**លោក អាកទ្បូ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ បាទដើម្បីបំភ្លឺសម្រាប់សហភាតារបស់ខ្ញុំផងដែរ សហព្រះ

រាជអាជ្ញាក៏ដូចជាសាក្សីផងដែរ។ ខ្ញុំអានឲ្យគាត់អម្បាញ់មិញនេះ អ្វីដែលគាត់និយាយនៅថ្ងៃទី២៣ វិច្ឆិកា គឺថាកាលនោះគាត់និយាយតែពីសំបុត្រតែមួយទេ។ ក៏ប៉ុន្តែនៅពេលសហព្រះរាជអាជ្ញានិយាយអម្បាញ់មិញនេះ គឺថាគាត់លើកឡើងពីសំបុត្រពីរខុសគ្នា។ អ៊ីចឹងមិនអាចទៅរួចទេ ព្រោះអង្គាលថ្ងៃទី២៣ វិច្ឆិកានោះគាត់និយាយតែពីលិខិតតែមួយទេ។ អ៊ីចឹងវាមិនអាចទៅរួចទេ។ អ៊ីចឹងសូមឲ្យច្បាស់លាស់ទាំងអស់គ្នា ដើម្បីកុំឲ្យនិយាយដោយឈរលើមូលដ្ឋានមានការភ័ន្តច្រឡំ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកមេធាវី។ មូលហេតុដែលខ្ញុំយោងទៅរកហេតុការណ៍ទី២ នោះខ្ញុំសូមដកស្រង់ដើម្បីកំណត់ត្រាតុលាការនោះ គឺដូចខាងក្រោមនេះ សូមដកស្រង់ "បន្ទាប់មកយោធាពីរនាក់បានត្រឡប់មកជាថ្មីម្តងទៀត ហើយបានអញ្ជើញគាត់ គឺអញ្ជើញលោក ចៅ សៅ ឲ្យត្រឡប់មកភ្នំពេញម្តងទៀត ហើយគាត់នៅតែបដិសេធ។ ចាប់ពីពេលនោះតទៅលោក ចៅ សៅ ក៏បានបាត់ខ្លួន"។ បាទនេះជាផ្នែកដែលខ្ញុំយោងទៅរកនោះនៅក្នុងប្រតិចារឹក ចម្លើយរបស់លោកដើមបណ្តឹងរដ្ឋប្បវេណី។ ហេតុដូច្នេះសូមលោកប្រធានមេត្តាអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីបំភ្លឺបន្ថែមថា តើនៅក្នុងលិខិតទី២នោះជាការអញ្ជើញអ៊ំរបស់គាត់ឲ្យមកភ្នំពេញដែរឬទេ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ដូច្នេះលោក ចៅ នី បើសិនខ្ញុំមិនយល់ច្បាស់ទេ សូមលោកកែតម្រូវខ្ញុំ។ តើត្រូវដែរឬទេដែលខ្ញុំយល់ថានៅពេលដែលយោធាត្រឡប់ទៅជួបគាត់ជាលើកទី២នោះ គឺដើម្បីសុំឲ្យចៅ សៅ ត្រឡប់មកភ្នំពេញជាលើកទី២ម្តងទៀតតាមដែលលោកឆ្លើយថាមានសំបុត្រទី២នោះ?

[១០:០១:១៧]

**ឆ៖** នៅពេលនោះ ខ្ញុំបានឮឈៀង ប្រាប់ខ្ញុំ គ្រាន់តែថាសំបុត្រទី១ និងទី២។ តែទី១ ខ្ញុំដឹងច្បាស់ ទី២ ខ្ញុំគ្រាន់តែប្រហែលជាសំបុត្រនេះអញ្ជើញអ៊ំ ចៅ សៅ នេះចូលទីក្រុងវិញដែរ។ ក៏ប៉ុន្តែគាត់បដិសេធអត់ចូលទេ លុះត្រាប្រជាពលរដ្ឋចូល។ ក៏ប៉ុន្តែដល់ពេលអាសំបុត្រទី២នោះទៅដល់ គាត់លែងឲ្យពូឈានទៅជាមួយគាត់។ គាត់ដេញពូឈានត្រឡប់ទៅជួបគ្រួសារគាត់វិញទៅ។ តែមិនដឹងអត្ថន័យហ្នឹងសំបុត្រនោះបំណងទៅលើ ចៅ សៅ យ៉ាងណា ឬមួយ ចៅ សៅ គាត់យល់នៅក្នុងសំបុត្រនោះ ថាមិនឲ្យតែកុងឡានគាត់រងគ្រោះជាមួយគាត់ ឬយ៉ាងណា ក៏ខ្ញុំអត់ដឹងដែរ។

**ស៖** សូមអរគុណដែលលោកបានបំភ្លឺចំណុចនេះជូនតុលាការ។ លោកក៏បាននិយាយផងដែរថា

លោកជឿថា លោក ខៀវ សំផន បានដឹងលោក ចៅ សៅ។ លោកបាននិយាយថា លោក ខៀវ សំផន បានទៅលេងលោក ចៅ សៅ ទៀតផងនៅក្នុងឆ្នាំ១៩៦០ ដែលលោក ខៀវ សំផន ក៏បញ្ជាក់ដែលថា គាត់បានចាកចេញពីភ្នំពេញហ្នឹងគឺឆ្នាំ១៩៦៧ទេ។ តើលោកអាចជម្រាបតុលាការបានទេថាតើសកម្មភាពការងារអ្វីខ្លះរបស់លោក ចៅ សៅ ចាប់ពីឆ្នាំ -- ចុងទសវត្សរ៍ឆ្នាំ១៩៦០ រហូតមកដល់១៩៧៥នោះ។ តើលោកអាចជម្រាបតុលាការបានដែរឬទេ?

**ឆ៖** កាលពេលនោះពួកខ្ញុំនៅតូចៗទេ។ ពេលដែលគាត់ជួបនឹង ខៀវ សំផន ម្ដាយខ្ញុំក៏នៅផ្ទះឈើ នៅខាងក្រោយផ្ទះលោក ចៅ សៅ ហ្នឹង។ គាត់ថា "ថ្ងៃហ្នឹងអ៊ំឯងជួប ខៀវ សំផន មកហូបបាយជាមួយគ្នាហើយ"។ ហើយអ៊ីចឹងគាត់ឲ្យពួកខ្ញុំទៅផ្ទះឈើខាងក្រោយហើយ។ អ៊ីចឹងខ្ញុំមិនដឹងគាត់ទំនាក់ទំនងរឿងអ្វីជាមួយ ចៅ សៅ – អ៊ំសៅ និងលោកអ៊ំ ខៀវ សំផន នោះ។ ខ្ញុំមិនដឹងទំនាក់ទំនងរឿងអ្វី គឺគាត់ទៅផ្ទះលោក ចៅ សៅ នៅទួលគោក ក្រោយផ្ទះ សុសស្ដែន គឺញឹកញាប់កាលណោះ។

[១០:០៣:៤៤]

**ស៖** តើលោកដឹងដែរឬទេអំពីមុខតំណែងរបស់លោក ចៅ សៅ ចាប់ពីឆ្នាំ១៩៧០ រហូតដល់១៩៧៥។ តើគាត់ធ្វើការអ្វី ឬក៏មុខរបរអ្វី?

**ឆ៖** ពី៧០ មក ៧៥នេះ ខ្ញុំដឹងថាគាត់ជាប្រធានធនាគារ។ ហើយក្រោយពីហ្នឹងមក គាត់នឹងធ្វើបង្កើតជាគណៈបក្សនយោបាយមួយ គាត់ជាប្រធានគណៈប្រជាធិបតេយ្យ។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ មិនដឹងគាត់ធ្វើអ្វីទៀត ខ្ញុំអត់ដឹង។

**ស៖** សូមអរគុណ។ ដោយហេតុថាការពិតមានសារៈសំខាន់ណាស់ ដែលថាតុលាការត្រូវតែទទួលបាននូវព័ត៌មានត្រឹមត្រូវឲ្យបានល្អបំផុត។ ខ្ញុំមានកាតព្វកិច្ចដើម្បីនឹងសួរលោកសំណួរដូចខាងក្រោមនេះ។ តាមសន្ទនារបស់ខ្ញុំជាមួយមេធាវីរបស់លោក ខ្ញុំយល់ថា ចៅ សៅ គឺជាឪពុកមាររបស់ប្រពន្ធរបស់លោក។ ហើយខ្ញុំសូមឲ្យលោកបំភ្លឺតុលាការ ដូច្នេះយើងចង់ដឹងឲ្យច្បាស់តើ ចៅ សៅ ជាឪពុកមាបង្កើតរបស់លោក ឬក៏ជាអ៊ំរបស់ប្រពន្ធលោកទេ?

**ឆ៖** គឺជាអ៊ំរបស់ប្រពន្ធខ្ញុំ គាត់ជាអ៊ំរបស់ប្រពន្ធខ្ញុំ។

**ស៖** សូមអរគុណ។ ខ្ញុំមិនមានសំណួរអ្វីទៀតទេ លោក ចៅ សៅ។ លោកប្រធានខ្ញុំអស់សំណួរនឹងសួរទៅដើមបណ្ដឹងរដ្ឋប្បវេណីហើយបាទ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីមានឱកាសសួរដេញដោលបន្ថែមលើដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ម៉ះដេវ ម៉ូហាន៖**

**ស៖** សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាលោកបានឆ្លើយយ៉ាងខ្លីៗរួចមកហើយទៅលើសំណួរដែលលោកត្រូវបានសួរ។ ហើយខ្ញុំនឹងសួរសំណួរមួយចំនួនពាក់ព័ន្ធនឹងសំណួរដែលសួរបន្តពីមេធាវីការពារក្តី។ ដើម្បីជាប្រយោជន៍ដល់អង្គជំនុំជម្រះលោកបានលើកឡើងពីខាងដើមថា ថៅ សៅ គឺជាអ៊ំរបស់ប្រពន្ធរបស់លោក ហើយគាត់គឺជាប្រធានធនាគារឥណទាន។ តើលោកអាចជម្រាបយើងខ្ញុំបន្ថែមទៀតដែរឬទេ អំពីកិត្តិយស ឬក៏កេរ្តិ៍ឈ្មោះរបស់គាត់នៅក្នុងចំណោមខ្មែរក្រោមនៅក្នុងទសវត្សរ៍៦០ និង៧០នោះ តើលោកអាចជួយពន្យល់បន្ថែមបានដែរឬទេ?

[១០:០៦:៥៧]

**លោក ថៅ នី៖**

**ឆ៖** អ៊ីចឹងខ្ញុំសូមជម្រាបមេធាវីថា លោក ថៅ សៅ គឺមនុស្សអស្ចារ្យ ដែលមនុស្សមកពីខ្មែរក្រោមគឺអស្ចារ្យនៅកម្ពុជា។ ពីព្រោះគាត់ជាមនុស្សយុត្តិធម៌ គាត់ជាមនុស្សមិនស៊ីសំណូក គាត់ធ្វើអ្វីដែលតាមកម្លាំងគាត់ដែលធ្វើបាន។ គាត់នឹងជួយបណ្តុះបណ្តាលដែលខ្មែរកម្ពុជាក្រោមមករស់នៅកម្ពុជានេះឲ្យបានរៀនសូត្រមានកន្លែងធ្វើការ ទីកន្លែងស្នាក់នៅ អ៊ីចឹងនៅទីនេះគាត់មានឈ្មោះល្បីល្បាញដែលនៅក្នុងភ្នំពេញនេះ។

**ស៖** សូមអរគុណ។ ដោយសារតែគាត់ល្បីឈ្មោះណាស់ក្នុងចំណោមខ្មែរក្រោម។ តើមានខ្មែរក្រោមណាមួយដែលធ្វើការជាមួយគាត់នៅធនាគារឥណទានដែរឬទេ? ដែលនៅទីនោះគាត់គឺជាប្រធានគ្រប់គ្រងនោះ?

**ឆ៖** នៅកាលនោះភាគច្រើនដែលមានខ្មែរកម្ពុជាក្រោមដែលធ្វើនៅក្នុងធនាគារឥណទានជាតិ។ ដូចជា បងយ៉ាង សព្វថ្ងៃគាត់នៅរស់។ ហើយ បងស៊ិន ខ្ញុំនេះ ថៅ ស៊ិន នេះគាត់ស្លាប់ក្នុងរបបលោកអ៊ំខៀវ សំផន ទៅ។ មានភាគច្រើនដែលខ្មែរកម្ពុជាក្រោមធ្វើនៅក្នុងឥណទានជាតិ។ ដូចជាលោក ថៅ បាន ក៏គាត់ធ្វើនៅខាង សូណាព្រីម ខាងលក់គ្រឿងសំណង់នៅទីនេះ ដែលផ្ទះដែលខ្ញុំជួលនៅជាមួយបង

ខ្ញុំជួលនៅផ្សារអូឡាំពិក។

[១០:០៨:៥០]

**ស៖** សូមអរគុណ។ ដើម្បីសួរឡើងវិញលោកបានឆ្លើយប្រាប់តុលាការរួចមកហើយថា ចៅ សៅ ធ្លាប់រស់នៅតំបន់ទួលគោកក្នុងអំឡុងពេលនោះ។ ហើយគាត់ខ្មែរក្រោមស្គាល់គាត់ច្រើនណាស់។ ហើយ ចៅ បាន រស់នៅម្តុំផ្សារអូឡាំពិក ហើយផ្ទះមួយនៅអូរឡាំពិកនោះម្តុំស្តាតអូឡាំពិកនោះគឺក៏ជា ម្ចាស់-- ដែលមាន ចៅ បាន នេះជាម្ចាស់កម្មសិទ្ធិលើផ្ទះមួយនៅជិតស្តាតអូឡាំពិក ហើយគាត់ក៏ធ្វើការ ជាមួយនឹងលោកចៅ សៅ ដែរតើអ៊ីចឹងដែរឬទេ?

**ឆ៖** លោក ចៅ បាន គាត់ធ្វើការផ្សេងពីលោកអ៊ំ ចៅ សៅ ទេ។ គាត់ធ្វើខាងសូណាព្រីម។ ពីដើមគេហៅថា សូណាព្រីម ប៉ុន្តែខ្ញុំមិនដឹងថាគាត់ខាងអីដែរ ហៅថា សូណាព្រីមទេ។ ក៏ប៉ុន្តែលោក ចៅ សៅ គាត់នៅខាងធនាគារ។ ក៏ប៉ុន្តែកូនក្មួយដែលអ្នកធ្វើការ អ្នកមកពីក្រោមបានមកគាត់បណ្តុះ បណ្តាលឲ្យជាប់ថ្នាក់បាក់ឌុបអីហ្នឹងនេះទៅ គាត់ឲ្យចូលធ្វើខាងធនាគារច្រើន។

[១០:១០:០០]

**ស៖** លោកបានឆ្លើយប្រាប់តុលាការពីខាងដើមថា តាមម្តាយរបស់លោក និងសាច់ញាតិរបស់ លោក លោកបានឮគេនិយាយថា "ចៅ សៅ ស្គាល់ ខៀវ សំផន ច្បាស់ណាស់ ហើយធ្លាប់ហូបបាយ ចុកអីជាមួយគ្នាទៀត"។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** នេះគឺម្តាយក្មេងខ្ញុំប្រាប់ច្បាស់ណាស់។ ដែលពេលណាក៏ដោយ ដែលគាត់ជួបនឹងអ្នកណា គាត់ប្រាប់ប្អូនៗស្រីរបស់គាត់ហើយ។ ម្តាយក្មេក គឺជាប្អូនស្រីរបស់គាត់ ពីព្រោះ ចៅ សៅ នេះគាត់ជា កូនកំព្រាម្តាយតាំងពីអាយុ៧ឆ្នាំ ហើយដូច្នេះហើយគាត់មានបងប្អូនបីនាក់ទេ។ ហើយគាត់ស្រលាញ់ពោះ ជាមួយគាត់ណាស់។ បីនាក់គ្នាគាត់ហ្នឹងគឺស្រឡាញ់បំផុត។ ក្រោយមកនៅតែម្តាយខ្ញុំទេ -- ម្តាយក្មេកខ្ញុំ ដែលគាត់ភៀសខ្លួនទៅកម្ពុជាក្រោមវិញនៅក្នុងឆ្នាំ៧៤ ដែលក្រោយមក ដល់ពេលរំដោះនេះគាត់អត់បាន នៅជាយ ចៅ សៅ ដល់៧៩ គាត់ឡើងមករក ចៅ សៅ, រកកូនគាត់។ កូនបាត់ទាំងអស់ដែលនៅក្នុងនេះ ក្នុងកម្ពុជានេះ។ ឡើងមកឆ្នាំ -- ម្តាយខ្ញុំគាត់ឈឺចាប់ ឆ្អត -- សឹងឆ្កួត។ អ៊ីចឹងហើយគាត់ជួយណាស់អ្នក ដែលមកខ្មែរកម្ពុជាក្រោម។

[១០:១១:២២]

**ស៖** សូមអរគុណ។ លោក ចៅ នី លោកឆ្លើយពីខាងដើមអំពីការផ្សាយតាមវិទ្យុរបស់វិទ្យុ

កម្ពុជានោះ កម្ពុជាប្រជាធិបតេយ្យនៅក្នុងឆ្នាំ៧៥ ក្រោយពីខ្មែរក្រហមកាន់កាប់អំណាច។ ហើយលោកបានឆ្លើយថា នៅក្នុងការផ្សាយវិទ្យុនោះ លោកក៏បានស្តាប់ឮឈ្មោះ ថៅ សៅ, ស៊ីសុវត្ថិ សិរិមតៈ ហើយ និង ចេង ហេង ដែលគេកោះហៅអ្នកទាំងបីនោះឲ្យត្រឡប់មកវិញ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ពិតមែននៅក្នុងថ្ងៃរំដោះ ១៧មេសា ហើយនោះ គឺគេផ្សាយរក សិរិមតៈ, ចេង ហេង នៅក្នុងនោះក៏មានផ្សាយនៅឈ្មោះលោក ថៅ សៅ ដែរ។ ក៏ប៉ុន្តែ ថៅ សៅ ផ្សាយប្រហែលជា៣ថ្ងៃគឺលែងផ្សាយទៅ។ ក្រោយមកគេនៅផ្សាយតែ សិរិមតៈ, ចេង ហេង នោះ គឺច្រើនថ្ងៃ គឺផ្សាយតាមវិទ្យុជាតិ។

[១០:១២:២៦]

**ស៖** ខ្ញុំយល់ហើយ។ ដើម្បីបញ្ជាក់ឡើងវិញ នៅពេលដែលលោកឮឈ្មោះ អ្នកទាំងបីនោះ គឺថា តើវិទ្យុជាតិនោះ គេមានផ្សាយថា សូមឲ្យអ្នកទាំងបីហ្នឹងវិលត្រឡប់មកទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** នៅកាលនោះ បើខ្ញុំមិនច្រឡំទេ គឺពីព្រោះគេផ្សាយឲ្យអ្នកទាំងអស់នេះឲ្យចូលមកទីក្រុងភ្នំពេញវិញ ពីព្រោះអ្នកនៅធ្វើការកន្លែងណាគេឲ្យធ្វើការនៅកន្លែងនុ៎ងវិញ។

**ស៖** ខ្ញុំដឹងថា តុលាការគាត់ដឹងច្បាស់ហើយ គេបានឆ្លើយពីមុនមកដែរ ក៏ប៉ុន្តែតាមលោកដឹងឮ តើអ្នកទាំងពីរដែលមានឈ្មោះ ចេង ហេង និងសិរិមតៈ នោះ ស៊ីសុវត្ថិ សិរិមតៈ នោះតើអ្នកទាំងពីរនេះជានរណាដែរតាមការដឹងរបស់លោក?

**ឆ៖** អ្នកទាំងពីរនេះ គឺកាលពីចន្លោះ៧០ មក ៧៥ នេះ គឺគាត់ជាថ្នាក់ដឹកនាំកំពូលនៅក្នុងរាជរដ្ឋាភិបាល លន់ នល់។

**ស៖** ដូច្នេះអ្នកទាំងពីរនេះ ជាមន្ត្រីរជាន់ខ្ពស់នៅក្នុងរបប លន់ នល់។ លោក ថៅ សៅ គឺជាប្រធានធនាគារដែលជនជាតិខ្មែរក្រោម។ បានន័យថា គេស្នើសុំឲ្យលោក ថៅ សៅ នេះវិលត្រឡប់មកភ្នំពេញវិញ ក្រោយពេលខ្មែរក្រហមកាន់អំណាច។ ហើយតើលោកដឹងទេ ហេតុអ្វីបានជាពីរបីថ្ងៃក្រោយពេលដែលផ្សាយវិទ្យុនុ៎ង គឺគេលេងហៅលើកឡើងអំពីឈ្មោះ ថៅ សៅ នេះម្តងទៀត។ តាមការដឹងឮរបស់លោក តើហេតុអ្វីបានជាដូច្នេះ?

[១០:១៤:២៧]

**ឆ៖** ក្រោយពីនោះមក ខ្ញុំលែងដឹងលែងយល់ទៀត ពីព្រោះអ្នកធ្វើការកំពូលដូចជា ចេង ហេង, ឡុង បូរ៉េត, ស៊ីសុវត្ថិ សិរិមតៈ នេះគាត់ជាអ្នកកំពូលដែរ ហើយអ្វីបានជាមាន ថៅ សៅ គាត់ជាប្រធាន

ធនាគារមួយតែប៉ុណ្ណោះទេ។ គេក៏កោះហៅ -- ប្រកាសហៅតាមវិទ្យុដែរ ហ្នឹងខ្ញុំមិនយល់ពីមូលហេតុពីរបស់របបកម្ពុជាប្រជាធិបតេយ្យដែរ។ ហើយឬមួយគាត់ជាខ្មែរក្រោម ជាជនជាតិខ្មែរក្រោមក៏គេកោះមកនេះ គឺគេយល់ឃើញថា ចៅ សៅ ជាខ្មែរកម្ពុជាក្រោម ក៏ខ្ញុំមិនដឹងដែរ។

**ស៖** ខ្ញុំសល់សំណួរពីរចុងក្រោយលោក ចៅ នី។ សំណួរដំបូង សូមឲ្យលោកគិតត្រឡប់ទៅក្រោយបន្តិចចំពោះលិខិតទី២ ដែលលោក -- សំបុត្រទី២ដែលលោកបានឆ្លើយខាងដើម មានពេលពីរដងនោះ ដែលមានអ្នកតែកុងឡានហ្នឹងគឺបានប្រាប់ថា ចៅ សៅ ម្តងជួបជាមួយនឹងទាហានខ្មែរក្រហម ហើយលើកទី២ បានផ្តល់លិខិតមួយច្បាប់ សំបុត្រមួយច្បាប់។ លើកទី២ ទាហាននោះបានជួបជាមួយនឹង ចៅ សៅ ហើយទាហានហ្នឹងបានឲ្យសំបុត្រហ្នឹងទៅ ចៅ សៅ។ លោកបានជម្រាបប្រាប់តុលាការថា លោក ចៅ សៅ ឲ្យអ្នកតាកុងឡានរបស់គាត់នោះ ត្រឡប់ទៅគ្រួសាររបស់គាត់វិញ។ ក្រោយពីហ្នឹងទៅ គឺគេមិនបានដឹងថាមានអ្វីកើតឡើងចំពោះលោក ចៅ សៅ ទេ។ គេរកលោក ចៅ សៅ ហ្នឹងលែងឃើញទៀតហើយ។ តាមការយល់ឃើញរបស់លោក ហេតុអ្វីបានជាលោក ចៅ សៅ នេះឲ្យតៃកុងឡានរបស់គាត់នេះវិលត្រឡប់ទៅរកគ្រួសាររបស់គាត់វិញ ហើយមិនឲ្យទៅតាមលោក ចៅ សៅ?

[១០:១៦:៤៦]

**ឆ៖** នេះខ្ញុំយល់ឃើញថាសំបុត្រទី២នេះប្រហែលជាមានបញ្ហាជាមួយលោក ចៅ សៅ។ ហេតុដូច្នេះហើយបានគាត់ដេញ ពូឈាន ជាតាកុងឡាននោះឲ្យត្រឡប់ទៅរកគ្រួសារ។ នេះខ្ញុំដូចលើកម្តងហើយម្តងទៀតថា នៅពេលនោះប្រហែលជាខ្មែរក្រហម គាត់ខាងកម្ពុជាប្រជាធិបតេយ្យនេះ គាត់នឹកឃើញថា ចៅ សៅ នេះជាខ្មែរកម្ពុជាក្រោម ហេតុដូច្នេះហើយប្រហែលជាគេយកទៅសម្លាប់ភ្លាមៗនៅក្នុងពេលនោះ ពេលដែលតាកុងឡាននេះបាទ។ នេះខ្ញុំគ្រាន់តែសន្និដ្ឋាន។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ គឺចង់សួរសំណួរជូនលោកតែម្តង សួរលោកផ្ទាល់តែម្តងលោក ចៅ នី។ នៅពេលនេះលោកមានឱកាសចូលមកចំពោះមុខតុលាការពីរដង ហើយនៅក្នុងពេលនេះនោះ គឺថាឆ្លើយតបសំណួរពាក់ព័ន្ធទៅនឹងលោក ចៅ សៅ។ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ហេតុអ្វីបានជាវាមានសារៈសំខាន់ដែលលោកចង់ស្វែងរកការពិតអំពីជំណឹងសាច់ញាតិរបស់លោក និងអ៊ំខាងប្រពន្ធរបស់លោកដែលឈ្មោះ ចៅ សៅ នោះ? សូមលោកជួយជម្រាបជូនតុលាការ។

[១០:១៨:០៨]

**ឆ៖** សូមជម្រាបលោកមេធាវី សូមជម្រាប ហេតុអ្វីបានខ្ញុំស្វែងរកក្រុមគ្រួសារដែលលោក ចៅ

សៅ ទាំងអស់ ពីព្រោះខ្ញុំមានការសោកស្ដាយណាស់។ ក្រុមគ្រួសារខ្ញុំកើតនៅកម្ពុជាក្រោម ក៏ប៉ុន្តែបាន អាយុប្រហែលជា៥ឆ្នាំ ៦ឆ្នាំ គាត់យកមកឲ្យនៅជាមួយ ថៅ សៅ ដើម្បីឲ្យរៀនសូត្រនៅកម្ពុជានេះ នៅភ្នំពេញនេះ។ ហេតុដូច្នេះហើយ មិនមែនដែលក្រុមគ្រួសារខ្ញុំតែប៉ុណ្ណោះទេ គាត់ជួយដែលខ្មែរក្រោមដទៃទៀតឲ្យមករៀនសូត្រនៅកម្ពុជានេះបានច្រើនៗគ្នា។ ពីព្រោះនៅកម្ពុជានេះ អ្នកណាក៏ដឹងថា លោក ថៅ សៅ មនុស្សចិត្តល្អ។ ឲ្យតែមានសាច់ញាតិ ឲ្យខ្មែរកម្ពុជាក្រោមឡើងមក គឺគាត់នឹងជួយបណ្ដុះបណ្ដាលហើយ។ ហេតុដូច្នេះហើយ ខ្ញុំសោកស្ដាយណាស់ដែលគ្រួសារខ្ញុំបាត់លោក ថៅ សៅ មួយ, មិនមែនតែមួយទេ បាត់ច្រើនគ្នា ក៏ប៉ុន្តែខ្ញុំសោកស្ដាយបំផុតទៅលើលោកអ៊ំ ថៅ សៅ។

[១០:១៩:២០]

**លោក ម៉ះដេវ ម៉ូហាន៖**

សូមអរគុណលោក ថៅ នី។

លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្ដល់វេទិកានេះបន្តទៅឲ្យលោក ពេជ អង្គ។ សូមអរគុណ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល ដើមបណ្ដឹងរដ្ឋប្បវេណី និងសាធារណជន។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** សូមជម្រាបសួរលោក ថៅ នី! ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរបញ្ជាក់បន្ថែមទៅលើសំណួរដែលត្រូវបានសួរកន្លងមកលើលោក។ ជាបឋមចង់សួរបញ្ជាក់អំពីបុគ្គលភាពរបស់លោក ឈាង ដែលជាអ្នកបើកបរ។ តើលោកធ្លាប់ជួបលោក ឈាង ហ្នឹងពីមុនទេ មុន ១៧ មេសា ឆ្នាំ១៩៧៥? ហើយប្រសិនបើលោកធ្លាប់ជួបគាត់ តើលោកយល់ថាគាត់ជាមនុស្សយ៉ាងម៉េចដែរ? ជាមនុស្សហ្មត់ចត់ដែរឬទេ?

[១០:២០:២៥]

**ឆ៖** កាលពីមុនថ្ងៃ១៧ មេសា ខ្ញុំមិនបានជួប ពូឈាង ទេ ប៉ុន្តែបើប្រពន្ធខ្ញុំគឺរស់នៅជាមួយពូឈាន ជាអចិន្ត្រៃយ៍។

**ស៖** តើប្រពន្ធរបស់លោកហ្នឹងមានយល់យ៉ាងដូចម្ដេចដែរពី ពូឈាង ហ្នឹង? ថាតើគាត់មានធ្លាប់និយាយអំពី ពូឈាង ជម្រាបលោកដែរឬទេ? ថាតើជាមនុស្សដែលនិយាយអ្វីដែលជាការពិតដែរឬ

ទេ? ជាមនុស្សហ្មត់ចត់ដែរឬទេនៅក្នុងការងាររបស់គាត់?

**ឆ៖** ប្រពន្ធរបស់ខ្ញុំបាននិយាយប្រាប់ខ្ញុំថា អ៊ុំខ្ញុំ ចៅ សៅ នេះមុននឹងរើសអ្នកបើកបរគឺគាត់បានយល់អំពីទឹកចិត្តមនុស្សច្បាស់ណាស់។ ពីព្រោះ ពូឈាង មនុស្សមិនចេះនិយាយកុហក ហើយក៏មិនចេះនិយាយលេងប៉ែប៉ោដែរ គឺមនុស្សគឺស្មោះត្រង់តែម្តង។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីគួរប្រើប្រាស់នូវពេលដែលដែលចែកឲ្យមានប្រសិទ្ធភាព មានប្រយោជន៍ក្នុងការស្វែងរកការពិតនៃរឿងក្តី ចៀសវាងប្រើប្រាស់នូវភស្តុតាងប្រយោល ឬក៏ពាក្យចចាមអារ៉ាមនៅក្នុងការដេញដោលហ្នឹង វាគឺទំនងជាមិនមានរួមវិភាគទានអ្វីនៅក្នុងការស្វែងរកការពិតទេ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ខ្ញុំសូមបំភ្លឺបន្តិច ដោយសារថាព័ត៌មានដែលលោក--

[១០:២១:៥៩]

**ប្រធានអង្គជំនុំ៖**

សូមតាំងសំណួរឲ្យបានត្រឹមត្រូវ ជាក់ច្បាស់ទៅ ប្រើប្រាស់វិធីសាស្ត្រនិងបច្ចេកទេសដើម្បីឲ្យអង្គជំនុំជម្រះហ្នឹងមានមូលដ្ឋានក្នុងការយកទៅពិចារណា។ ចៀសវាងប្រើប្រាស់នូវប្រព័ន្ធនៃការសំណួរដែលសួរដោយយោងផ្អែកទៅលើពាក្យចចាមអារ៉ាម ឬក៏ភស្តុតាងប្រយោលឆ្ងាយបែបនេះ។ មិនសាកសមនឹងការប្រើប្រាស់ពេលវេលាដ៏មានតម្លៃនៅអង្គជំនុំជម្រះវិសាមញ្ញនេះទេ។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** លោក ចៅ នី នៅពេលដែលលោកជួបជាមួយលោក ឈាង នៅឆ្នាំ១៩៧៩ លោកបានបញ្ជាក់ថាគឺលោកបានជួបនៅក្នុងពេលនោះ គឺមានវត្តមានប្រពន្ធរបស់លោក ហើយនិងម្តាយក្មេករបស់លោកជួបជាមួយនឹងលោក ឈាង។ ថាតើពេលនោះអ្នកទាំងបីនោះយល់ថាអ្វីដែលលោក ឈាង និយាយនោះគឺជា គាត់និយាយជាការពិត ឬក៏និយាយដោយមានលក្ខណៈហ្មត់ចត់ដែរឬទេ?

[១០:២៣:១៣]

**លោក ចៅ នី៖**

**ឆ៖** ខ្ញុំយល់ថា ពូឈាន គាត់គឺនិយាយការពិត។ ពីព្រោះគាត់នៅជាមួយ ចៅ សៅ នេះបើកឡានតាំងពី ចៅ សៅ គាត់ធ្វើជាប្រធានធនាគារឥណទានជាតិហ្នឹងមក គឺពូឈាន ហ្នឹងបើកឡានឲ្យ ចៅ

E1/196.1

សៅ ហ្វឹងរហូត។ ហេតុដូច្នេះហើយខ្ញុំថា ពូឈាន គាត់គឺជាមនុស្សមិននិយាយកុហក គឺនិយាយពិត។

**ស៖** ខ្ញុំចង់បញ្ជាក់ថែមបន្តិចទៀតថា នៅក្នុងព័ត៌មានដែល ពូឈាង ដែលបានជូនដល់លោកហ្វឹង ថាតើគាត់មានបញ្ជាក់ថាទាហានទាំងពីរនាក់នោះ គឺជាទាហាននៅខាងណាដែរទេ?

**ឆ៖** គឺគាត់មិនបានបញ្ជាក់ថា គាត់ -- មិនដឹងទាហានខាងណាទេ ក៏ប៉ុន្តែពាក់ឈុតខ្មៅ និងស្ពាយកាំភ្លើងអាកា មានកន្សែងក្រហមព្ណ័ក ប្រហែលគាត់ថាកងទ័ពរំដោះគេ កងទ័ពខ្មែរក្រហម។ គាត់មិនដឹងមិនមែនកងទ័ពណាមកបន្លំបានទេ ពីព្រោះថ្ងៃនោះគឺជោគជ័យរបស់កម្ពុជាប្រជាធិបតេយ្យទៅហើយ។

[១០:២៤:២៧]

**ស៖** ខ្ញុំមានសំណួរពីរទៀតទេសម្រាប់លោក។ សំណួរទី-- មុនចុងក្រោយ គឺថាតើក្នុងចំណោមមេដឹកនាំខាងខ្មែរក្រហម ថាតើអ្នកណាដែលជាអ្នកមានទំនាក់ទំនងជិតស្និទ្ធជាងគេជាមួយអ៊ំរបស់លោកហ្វឹង? តើលោកអាចរៀបរាប់បានមួយចំនួនទេ អ្នកដែលមានទំនាក់ទំនងជិតស្និទ្ធ?

**ឆ៖** សូមជម្រាបលោកសហមេធាវីនាំមុខ ខ្ញុំថាអ្នកទំនាក់ទំនង នៅក្នុងរបបខ្មែរក្រហមជាមួយអ៊ំខ្ញុំនោះ មានលោកអ៊ំ ខៀវ សំផន មួយទេដែលជិតស្និទ្ធជាមួយលោកអ៊ំ ថៅ សៅ របស់ខ្ញុំ។

**លោក ពេជ អង្គ៖**

បាទ ថាតើអ្វីដែល -- បាទ ខ្ញុំនឹងមិនសួរសំណួរចុងក្រោយរបស់ខ្ញុំទេ។ ហើយខ្ញុំសូមបញ្ចប់សំណួររបស់ខ្ញុំពេលនេះ។

សូមអរគុណលោកប្រធាន សូមអរគុណលោកដើបបណ្តឹងរដ្ឋប្បវេណីដែលខំប្រឹងឆ្លើយនូវសំណួររបស់យើងខ្ញុំ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

មេធាវីការពារក្តី ខៀវ សំផន មានអីចង់បន្ថែមទេ?

**លោក អាកទ្ធរ វែកកែន៖**

បាទលោកប្រធាន អត់មានអីចងបន្ថែមទេលោកប្រធាន។

[១០:២៦:១២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះអង្គជំនុំជម្រះបានជម្រាបជូនលោករួចហើយអម្បាញ់មិញនេះ គឺថាអង្គជំនុំជម្រះនៅតែផ្តល់ឱកាសជូនលោកក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណីដើម្បីលោកមាន -- អាចប្រើសិទ្ធិ

របស់លោកក្នុងការថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខវេទនា និងស្ថានភាពព្យសនកម្មទាំងឡាយដែលកើតមានចំពោះលោក។ ហើយជាអាទិ៍ខូចខាតខាងផ្លូវចិត្ត ផ្លូវកាយសម្ភារៈ ការព្យសនកម្មផ្ទាល់ខ្លួនដែលជាបច្ច័យដោយផ្ទាល់នៃបទឧក្រិដ្ឋ និងកើតមានពិតប្រាកដរហូតដល់បច្ចុប្បន្នដែលពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលចោទប្រកាន់ទៅលើជនចាប់ចោទដែលប៉ះពាល់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។ សូមអញ្ជើញ!

[១០:២៧:១១]

**លោក ចៅ នី៖**

សូមជម្រាបលោកចៅក្រម! ការទុក្ខសោកដែលខ្ញុំឆ្លងកាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ បើរៀបរាប់ទៅវាមិនអស់មិនហើយទេ។ ក៏ប៉ុន្តែការទុក្ខសោកដែលខ្ញុំបាត់បង់បងប្អូន គ្រួសារនៅក្នុងរបបនោះ គឺការឈឺចាប់រហូតមកដល់សព្វថ្ងៃនេះ គឺនៅតែការឈឺចាប់នឹកឃើញ។ កាលពីមុនខ្ញុំខំបំភ្លេចដែរតាំងពីឆ្នាំ៧៩ រហូតមកដល់ឆ្នាំ៨៥, ៨៦ក៏ខ្ញុំបំភ្លេច ខំបំភ្លេច ដើម្បីកុំឲ្យនឹកឃើញរឿងដែលអតីត-កាល រហូតមកដល់មានតុលាការ រដ្ឋាភិបាលបង្កើតតុលាការកូនកាត់មានអង្គការសហប្រជាជាតិនិងជាតិ បង្កើតតុលាការនេះឡើង ធ្វើឲ្យខ្ញុំនឹកឃើញដែលការឈឺចាប់របស់ខ្ញុំជាមួយរបបកម្ពុជាប្រជាធិបតេយ្យ។ ហេតុដូច្នេះហើយ បងប្អូនខ្ញុំពីជំនាន់មុន ឪពុកធំ ឪពុកមា បងប្អូនអីហ្នឹង គាត់សុទ្ធតែអ្នកមានមុខមាត់នៅក្នុងការងាររដ្ឋាភិបាលកម្ពុជា។ ក្រោយពីថ្ងៃ១៧ មេសា មករហូតមកដល់ឆ្នាំ៧៩ កងទ័ពរដ្ឋាភិបាលបានរំដោះមក។ ខ្ញុំបាត់អស់បងប្អូនក្រុមគ្រួសារអស់រលីង។ ហេតុដូច្នេះហើយ ការឈឺចាប់របស់ខ្ញុំនៅតែឈឺចាប់ គ្មានពេលណាស្រាក។

[១០:២៨:៤៨]

ដល់ពេលនេះហើយ ខ្ញុំបានឡើងធ្វើសក្ខីកម្ម ចង់សួររកឪពុកមាដែលធ្លាប់ចិញ្ចឹមបីបាច់ថែរក្សាពីតូច ក្រុមគ្រួសារខ្ញុំ ទាំងគ្រួសារប្រពន្ធខ្ញុំទាំងអស់ ដើម្បីរកអដ្ឋិធាតុគាត់ដើម្បីឧទ្ទិសមផលឲ្យគាត់ នៅតែមិនបានដឹង មិនបានឮ។ ហេតុដូច្នេះហើយ ខ្ញុំនៅការឈឺចាប់របស់ខ្ញុំគឺនៅជាប់រហូត។ នៅក្នុងពេលនោះគ្រាន់តែទៅជាមួយលោក ចៅ សៅ នេះមានបងបង្កើតប្រពន្ធខ្ញុំពីរនាក់ គាត់ទៅស្លាប់ជាមួយគាត់។ ក្មួយពីរនាក់ក៏ទៅស្លាប់ជាមួយ ចៅ សៅ។ អ៊ីចឹងហេតុដូច្នេះហើយ ពូនៅពោធិ៍សាត់នោះក៏ស្លាប់ ចូលមកបានតែបីថ្ងៃ គេសម្លាប់ចោលហើយ។ ឲ្យតែខ្មែរកម្ពុជាក្រោមគឺគេសម្លាប់ចោលហើយ ហេតុអីបានជាគេគុំ ខាងកម្ពុជាប្រជាធិបតេយ្យ ខាងខ្មែរក្រហម គាត់ស្អប់ខ្មែរកម្ពុជាក្រោមម្ល៉េះ។ សូម្បីតែក្មេងមិនទាន់

ដឹងអីផងក៏សម្លាប់ចោលដែរ ឲ្យតែខ្មែរកម្ពុជាក្រោម។ ហេតុដូច្នេះហើយលោកអ៊ំ ខៀវ សំផន គួរតែយល់ហើយ។ លោកធ្លាប់ហូបបាយខ្មែរកម្ពុជាក្រោមដែរ មិនមែនថាមិនមែនធ្លាប់មកហូបទេ។ លោកនៅក្នុងរបបនោះហេតុអីបានមានអ្នកណាដែលគេបង្ខំឲ្យគេសម្លាប់ខ្មែរកម្ពុជាក្រោម។ លោកអ៊ំគួរដឹងហើយ។ ខ្មែរកម្ពុជាក្រោមគាត់មក នេះដើម្បី--

**ប្រធានអង្គជំនុំ៖**

គឺលោកសូមតម្រង់នូវការសេចក្ដីឈឺចាប់និងទុក្ខសោកវេទនារបស់លោកឲ្យចំបញ្ហាចៀសវាងបង្កើតនូវអង្គហេតុថ្មីទៀតដោយសារលោកមិនតម្រង់នូវសេចក្ដីថ្លែងទុក្ខសោករបស់លោកឲ្យចំបញ្ហាចំគោលបំណងនៃពេលវេលាដែលអង្គជំនុំជម្រះហ្នឹងហើយទើបលោកបាននាំឲ្យមានកើតមាននូវសវនាការបន្ថែមនៅថ្ងៃនេះ។ អ៊ីចឹងសូមលោកបង្ហាញតែភាពពាក់ព័ន្ធទៅនឹងបទល្មើស ហើយនិងបញ្ហាព្យសនកម្មក្រុមគ្រួសារញាតិមិត្តហើយនិងការឈឺចាប់ប៉ុណ្ណោះបានហើយ ចៀសវាងឈានដល់ការបង្កើតអង្គហេតុថ្មីទៀត នីតិវិធីនឹងប្រព្រឹត្តទៅបន្ថែមបន្តទៅទៀតជាមិនខាននោះឡើយ។

[១០:៣១:១៣]

**លោក ចៅ នី៖**

ការទុក្ខសោករបស់ខ្ញុំគឺគ្មានអ្វីក្រៅពីបាត់បង់សាច់ញាតិឪពុកម្ដាយ ឪពុកមា ហ្នឹងពូរបស់ខ្ញុំទេ។ អ៊ីចឹងខ្ញុំគ្មានអ្វីតទៅមុខទៀតទេ។ ខ្ញុំបាទសូមនិយាយតែប៉ុណ្ណឹងសិនបាន។ សូមអរគុណលោកចៅក្រម។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣២:០៩]

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោក ចៅ នី ការស្ដាប់សក្ខីកម្មបន្ថែមរបស់លោករហូតដល់ពេលនេះបានចប់ហើយ ហើយការវត្តមានរបស់លោកនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ លែងមានភាពចាំបាច់ទៀតហើយ។ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ។ លោក ចៅ នី អាចវិលត្រលប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកជួបតែសំណាងល្អ មានសុខភាពល្អ មានសេចក្ដីសុខរីកចំរើន។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ចៅ នី វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏ទីកន្លែងណាដែលជាគោលដៅដែលគាត់មាន

បំណងចង់ទៅ។ ហើយកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះដល់ពេលសម្រាកហើយដោយសារមូលហេតុថ្ងៃនេះគឺអង្គជំនុំជម្រះមិនបានគ្រោងនូវដើមបណ្តឹងរដ្ឋប្បវេណី ឬក៏សាក្សីបន្ថែមទេ។ ហើយកិច្ចការអង្គជំនុំជម្រះគឺមានច្រើន ដូច្នេះគឺកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះគឺអង្គជំនុំជម្រះផ្អាកសវនាការថ្ងៃនេះត្រឹមនេះ។

មានបញ្ហាអីទៀតហើយលោកតំណាងសហព្រះរាជអាជ្ញា?

[១០:៣៣:៣០]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធានជាទីគោរព! ខ្ញុំសូមអធ្យាស្រ័យដែលពន្យារពេលការបញ្ចប់សវនាការនេះ។ ខ្ញុំលើកឡើងដោយខ្លីទេ។ ខ្ញុំក្រោកឈរឡើងដោយសារតែយើងមិនមានការជូនដំណឹងនៅក្នុងពេលសវនាការនេះដែលថា ខៀវ សំផន នឹងឆ្លើយតបទៅនឹងសំណួរ។ ជាការពិត ដូចដែលលោកប្រធានបានបញ្ជាក់រួចមកហើយការពីលើកមុននោះ គឺថាគាត់មិនបានអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះឡើយ។ ហេតុផលដែលខ្ញុំក្រោកឈរឡើងគឺដោយហេតុថា ខ្ញុំចង់ឲ្យប្រាកដថានៅក្នុងពេលអនាគតដំណើរការនីតិវិធីនៅពេលអនាគតនោះគឺការចោទប្រកាន់ថា សហព្រះរាជអាជ្ញាបោះបង់សិទ្ធិមិនធ្វើការពិនិត្យទៅលើជនជាប់ចោទ។ តាមវិធាន៩០ អង្គជំនុំជម្រះមានសិទ្ធិក្នុងការពិនិត្យទៅលើជនជាប់ចោទ ភាគីសហព្រះរាជអាជ្ញាក៏មានសិទ្ធិក្នុងការដេញដោលសួរសំណួរទៅកាន់ជនជាប់ចោទផងដែរ។ ខ្ញុំក្រោកឈរឡើងដើម្បីបញ្ជាក់ថាយើងទាំងអស់គ្នាបានដឹងអំពីនីតិវិធីនេះ ហើយយើងមានសិទ្ធិនេះទាំងអស់គ្នា។ ហើយជាពិសេសនោះគឺសូមស្នើសុំដោយគោរពដល់អង្គជំនុំជម្រះគិតពិចារណាទៅលើករណីដូចដែលបាន ដូចដែលជនជាប់ចោទបានឆ្លើយនេះនៅក្នុងការវិភាគសវនាការរបស់យើង។ ដូច្នេះវាមានសារប្រយោជន៍ណាស់ ដែលថាជនជាប់ចោទគួរតែជូនដំណឹង ឬក៏ក្រុមមេធាវីការពារក្តីគួរតែជូនដំណឹងឲ្យបានច្បាស់លាស់អំពីការធ្វើដូច្នេះដើម្បីឲ្យយើងត្រៀមខ្លួនរួចជាស្រេចនៅក្នុងនីតិវិធីរបស់យើងខ្ញុំ។ នេះជាការលើកឡើងរបស់ខ្ញុំលោកប្រធាន។

[១០:៣៥:១២]

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញចេញចុះ អញ្ជើញចាកចេញចុះលោក ចៅ នី!

បាទ អញ្ជើញភាគីពាក់ព័ន្ធដទៃទៀត សូមអញ្ជើញមានមតិយោបល់។ អញ្ជើញលោកមេធាវី

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន! សម្រាប់ខាងដើមបណ្តឹងរដ្ឋប្បវេណីនៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីមានសំណួរ ហើយសំណួរនេះត្រូវសួរជូនទៅជនជាប់ចោទ។ សំណួរ ដើមបណ្តឹងរដ្ឋប្បវេណីលើកសំណួរដោយយល់អំពីសារៈសំខាន់ ថាបើសិនជនជាប់ចោទឆ្លើយយើងនឹងអាចដោះស្រាយបញ្ហាផ្លូវចិត្តរបស់គាត់បានមួយចំនួន។ ដូច្នេះវាជាសារៈសំខាន់មួយណាស់សម្រាប់ខាងដើមបណ្តឹងរដ្ឋប្បវេណីដែលមានការឆ្លើយអំពីជនជាប់ចោទនេះ ហើយជាការល្អមួយដែរ ហើយដោយគាំទ្រទៅលើអ្វីដែលសហព្រះរាជអាជ្ញាបានលើកនេះ ជាការល្អដែរ។ ប្រសិនបើមុននឹងឆ្លើយនេះ លទ្ធភាពនេះ គួរផ្តល់ជាព័ត៌មានទៅដល់យើងខ្ញុំដែលជាភាគីទាំងអស់គ្នាផងដែរ។

[១០:៣៦:៣៧]

ហើយម្យ៉ាងទៀត ខ្ញុំគ្រាន់តែសុំធ្វើការកត់សម្គាល់មួយទៀត នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីលើកអំពីព្យសនកម្ម ឬការឈឺចាប់របស់គាត់ វាជាការធម្មតាទេដែលអាចក្នុងពេលដែលគាត់លើកអំពីបញ្ហាអស់នេះ មានអង្គហេតុអ្វីមួយដែលពាក់ព័ន្ធទៅនឹងព្យសនកម្មរបស់គាត់ត្រូវបានលើកឡើង។ ដូច្នេះយើងខ្ញុំសូមគ្រាន់តែកត់សម្គាល់ថា នេះគ្រាន់តែជាការធម្មតាដែលអាចកើតមានទេ ហើយវាមិនអាចជាកំហុសអ្វីមួយ ឬក៏បញ្ហាអ្វីមួយដែលគាត់និយាយក្រៅអំពីវិសាលភាពនៃការថ្លែងអំពីការឈឺចាប់ ឬក៏ព្យសនកម្មរបស់គាត់នោះទេ។ បាទ ខ្ញុំសូមលើកតែប៉ុណ្ណេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារក្តី ខៀវ សំផន!

**លោក អាកទូរ វែកកែន៖**

បាទ អម្បាញ់មិញនេះ ខ្ញុំអត់យល់អំពីផ្នែកចុងក្រោយដែលសហភាគាខ្ញុំនិយាយអម្បាញ់មិញនេះ ខ្ញុំមិនដឹងថា គាត់និយាយពីអ្វី។ បាទ ខ្ញុំ--

[១០:៣៨:០៦]

**ប្រធានអង្គជំនុំ៖**

សូមឲ្យគាត់និយាយម្តងទៀតទេ? អង្គជំនុំជម្រះក៏ស្តាប់មិនសូវយល់ដែរ។

លោកមេធាវី សូមនិយាយឲ្យច្បាស់លាស់ ហើយឲ្យមានឲ្យទំនងឲ្យយល់បានផង ហើយបើ

និយាយពិបាកយល់យ៉ាងនេះវាពិបាកនឹងរកអ្នកបកប្រែភាសាមួយជាន់ទៀតណាស់។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន ខ្ញុំនឹងនិយាយឲ្យច្បាស់នៅពេលនេះ។ ដើមបណ្ដឹងរដ្ឋប្បវេណី គាត់បាននិយាយអំពីព្យសនកម្មរបស់គាត់ពីលើកមុន ហើយនៅក្នុងផ្នែកនៃការនិយាយអំពីព្យសនកម្មរបស់គាត់ ជាធម្មតាព្យសនកម្មវាត្រូវភ្ជាប់ទៅនឹងអង្គហេតុ។ ដូច្នេះអង្គហេតុអាចមានចាស់ មានថ្មី នេះជាការធម្មតា។ ដូច្នេះនេះជាការសង្កេតរបស់យើងខ្ញុំ។ ហើយប្រសិនបើគាត់លើកអ្វីដែលជាព្យសនកម្មថ្មី មិនគួរចាត់ទុកថា (សូមទោស) អង្គហេតុថ្មីមិនគួរចាត់ទុកថា អង្គហេតុថ្មីនេះ គឺជាកំហុសរបស់គាត់ណាមួយដែលគាត់និយាយក្រៅអំពីវិសាលភាពនៃការលើកអំពីព្យសនកម្មនោះទេ ហើយដែលជាបញ្ហានាំឲ្យមានកើតឡើងនៅការសវនាការពេលក្រោយទៀតនោះទេ។ ដូច្នេះនេះគឺជាគំនិតរបស់ខ្ញុំ ហើយខ្ញុំសង្ឃឹមថាអ្វីដែលខ្ញុំលើកហ្នឹង គឺច្បាស់ ហើយ -- បាទ សមអរគុណលោកប្រធាន។ ប្រសិនបើខ្ញុំលើកមិនច្បាស់ខ្ញុំនឹងបំភ្លឺបន្ថែមទៀត។ សូមអរគុណលោកប្រធាន។

[១០:៣៩:៤១]

**ប្រធានអង្គជំនុំ៖**

ក្នុងនាមប្រធានអង្គជំនុំជម្រះយើងសង្ឃឹមថា លោកក្នុងនាមជាមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនឹងមានគោលការណ៍តម្រង់នូវ -- ណែនាំនូវកូនក្ដីរបស់លោកកនៅក្នុងការធ្វើសេចក្ដីថ្លែងការណ៍អំពីទុកសោកវេទនា ឬក៏អំពីព្យសនកម្មនេះបានសមស្រប បានរលូន ហើយនិងចំបញ្ហា។ ការដែលងាកខុសពីបញ្ហានោះ នាំឲ្យកើតនូវសវនាការនេះមួយព្រឹកទៀត ដោយសារមូលហេតុនៃការបង្កើតឡើងនូវអង្គហេតុថ្មី ដែលទំនងជាកូនក្ដីរបស់លោកមិនទទួលបានការណែនាំពីលោកទេ អំពីលំដាប់ អំពីរបៀបក្នុងការធ្វើសេចក្ដីថ្លែងការណ៍ អំពីព្យសនកម្ម ហើយនិងការឈឺចាប់ ហើយនិងការផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ។

យើងបារម្ភថាបញ្ហានេះវាអាចកើតទៀត ប្រសិនបើយើងមិនតម្រង់ទេ នោះវានឹងអាចកើតសាជាថ្មីទៀត ដែលនាំឲ្យមានសំណើសុំស្ដាប់សក្ខីកម្មបន្ថែម ដើមបណ្ដឹងរដ្ឋប្បវេណីមកនិយាយម្នាក់បន្ថែមមួយព្រឹក។ ប្រសិនបើថែមលើដើមណ្ដឹងរដ្ឋប្បវេណី១០នាក់ វាអាច១០ព្រឹកទៀត។ អ៊ីចឹងការប្រើប្រាស់ពេលវេលាដែលអង្គជំនុំជម្រះប្រឹងប្រែងដើម្បីបង្កើនល្បឿនកិច្ចដំណើរការនិតិវិធីនេះ កិច្ចសវនាការនេះវានឹងអាចមានផលប៉ះពាល់ វាធ្វើឲ្យអូសបន្លាយពេលវេលា។

សូមអញ្ជើញលោកមេធាវីការពារក្តីលោក ខៀវ សំផន!

[១០:៤១:២៨]

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ខ្ញុំគិតថាវាជាការពិភាក្សាមួយដ៏សំខាន់។ អាស្រ័យហេតុដូច្នេះហើយបានជាដើមសប្តាហ៍នេះ ខ្ញុំបាននិយាយពីរឿងទាំងអស់នេះ។ បាទ ចំពោះយើងគឺថាត្រូវតែធ្វើការជម្រះសេចក្តីមួយដើម្បីឲ្យជនជាប់ចោទត្រូវបានកាត់សេចក្តី ឬក៏កាត់ទោស ក៏ប៉ុន្តែចំពោះយើងការជម្រះសេចក្តីមួយដែលមានដើមបណ្តឹងរដ្ឋប្បវេណី ធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណីនេះក្លាយជាជនរងគ្រោះផ្នែកផ្លូវច្បាប់នោះ ខ្ញុំអម្បាញ់មិញនេះ លោក ពេជ អង្គ នោះក៏បានលើកឡើងដែរថា សប្តាហ៍ក្រោយអង្គជំនុំជម្រះបានកោះហៅដើមបណ្តឹងរដ្ឋប្បវេណីឲ្យមកនិយាយតែពីការឈឺចាប់របស់ខ្លួនតែប៉ុណ្ណោះ។ ក៏ប៉ុន្តែចំពោះយើងខាងការពារក្តីវិញនេះ គឺជាការលោតផ្លោះមួយ ព្រោះថាជាមួយដើមបណ្តឹងរដ្ឋប្បវេណីសប្តាហ៍ក្រោយនេះ គឺថាយើងដូចជាធ្វើការកាត់ក្តីខុសហើយ ព្រោះថា--

**ប្រធានអង្គជំនុំ៖**

បញ្ហាដែលលើកឡើងអម្បាញ់មិញនេះគឺសហព្រះរាជអាជ្ញាជាអ្នកលើកឡើង។ បញ្ហានោះពាក់ព័ន្ធជាមួយនឹងសិទ្ធិនៅស្ងាមមិនឆ្លើយតប ឬក៏អនុវត្តនូវសិទ្ធិឆ្លើយតប ឬក៏សិទ្ធិនៅស្ងៀមមិនឆ្លើយតបមានលក្ខខណ្ឌ។ ករណីខ្លះឆ្លើយតប ករណីខ្លះមិនឆ្លើយតប។ នេះជាបញ្ហាដែលលើកឡើងដោយតំណាងសហព្រះរាជអាជ្ញា។ ចំណែងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គោលបំណងគាត់គ្រាន់តែគាំទ្រទេ ហើយការកត់សង្កេតរបស់គាត់គឺជាពាក់ព័ន្ធជាមួយនឹងកិច្ចដំណើរការរបស់អង្គជំនុំជម្រះ គឺយើងជាអ្នកតម្រង់កូនក្តីរបស់គាត់ឲ្យនិយាយចំបញ្ហា ហើយមានការកត់សម្គាល់ថា បើយើងបណ្តោយទៅគាត់នឹងបង្កើតអង្គហេតុថ្មី លោកនឹងអាចស្នើសុំស្តាប់គាត់បន្ថែមទៀត ពីព្រោះមិនទំនងជាមិនមានការតម្រង់ឲ្យកូនក្តីរបស់ខ្លួនឡើងធ្វើការបង្ហាញអំពីទុក្ខសោកវេទនា ឬ/និងអំពីព្យសនកម្មនោះឡើយ។

[១០:៤៤:១០]

អ៊ីចឹងរឿងនោះ គឺជារឿងដោយឡែកបន្ទាប់បន្សំទេ។ គោលបំណងរបស់គាត់ គឺគាំទ្រលើមតិយោបល់ដែលលើកឡើងដោយតំណាងសហព្រះរាជអាជ្ញា លើបញ្ហារក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបជារៀងរហូត ដាច់ខាត ឬក៏ដោយលក្ខខណ្ឌ។ តើលោកតបបញ្ហាហ្នឹងយ៉ាងដូចម្តេច? ករណីខ្លះឆ្លើយតប ករណីខ្លះនៅស្ងៀមមិនឆ្លើយតប?

**លោក អាកទូរ វែកកែន៖**

បាទ អ្វីដែលខ្ញុំចង់និយាយនោះគឺថា យើងនិយាយអំពីការឈឺចាប់ ហើយមិននិយាយអំពីអង្គហេតុដែលទាក់ទងនឹងការឈឺចាប់នេះ។ ដើមបណ្ដឹងរដ្ឋប្បវេណីអម្បាញ់មិញ មេធាវីអំមិញក៏គាត់និយាយពីបញ្ហានេះដែរ។ ឥឡូវនេះទាក់ទងទៅនឹងសំណើ ឬក៏មិនសំណើ ខ្ញុំយល់មិនសូវច្បាស់ដែរ ឬក៏អំពីឱកាសរបស់សហព្រះរាជអាជ្ញាក្នុងការដែលថាគាត់លះបង់សិទ្ធិមិនចោទសំណួរទៅលោក ខៀវ សំផន ត្រង់ចំណុចនេះសំណើនេះវាមានច្រើនកម្រិត។ ក៏ប៉ុន្តែកំណត់សម្គាល់របស់គាត់នោះ អម្បាញ់មិញបើតាមខ្ញុំយល់ គាត់ចង់ថាសុំឲ្យរៀបចំសវនាការឲ្យស្រួល។

[១០:៤៥:៥១]

ហើយបើរហូតដល់ពេលនេះ គឺលោកប្រធានមួយថ្ងៃទៅមួយថ្ងៃនេះ សហភាតារបស់ខ្ញុំទាំងអស់នោះមិនដឹងថាកម្មវិធីសវនាការនោះយ៉ាងម៉េចទេ។ យើងដឹងត្រឹមតែសប្ដាហ៍ក្រោយទេ យើងមិនដឹងថាយើងទៅណាទេ។ មិនដឹងថាចំនួនសាក្សីដែលនឹងមកផ្ដល់សក្ខីកម្មនៅទីនេះមានប៉ុន្មាន ហើយមិនដឹងការកាត់នេះចប់នៅពេលណាទេ ឮតែសំឡេងចចាមអារ៉ាមតែប៉ុណ្ណោះ។ អ៊ីចឹង ការប្រជុំរៀបសវនាការនោះយើងធ្វើឡើងដើម្បីឲ្យដឹងថាទៅថ្ងៃធ្វើអី។ អ៊ីចឹងតើមានសំណើរបស់ភាគីទាំងអស់មកគ្រប់ទិសទី ប៉ុន្តែឧទាហរណ៍ដូចសំណើថ្ងៃមកអ៊ីចឹង ខ្ញុំក៏ធ្វើសំណើដែរថ្ងៃនេះដែរ។ ខ្ញុំចង់ដឹងថាឥឡូវនេះយើងដល់ណាហើយ។ យើង--

**ប្រធានអង្គជំនុំ៖**

ឥឡូវលោកកំណត់នូវរបៀបក្នុងការឆ្លើយតប គឺលោកត្រឹមតែមានបំណងឆ្លើយតបជាមួយនឹងថ្លឹងថ្លែងឡើងវិញ។ អង្គជំនុំជម្រះអនុញ្ញាតឲ្យលោកធ្វើការកត់សម្គាល់ ឬក៏ឆ្លើយតបទៅនឹងសំណើសុំ ឬក៏អ្វីដែលលោកបានលើកឡើងដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធជាមួយនឹងសិទ្ធិនៅស្ងៀមមិនឆ្លើយតប ឬក៏សិទ្ធិនៅស្ងៀមមិនឆ្លើយតបមានលក្ខខណ្ឌរបស់កូនក្ដីរបស់ខ្លួនចាប់ពីពេលនេះទៅរហូតដល់កិច្ចដំណើរការសវនាការចប់។

[១០:៤៧:២១]

នៅក្នុងកិច្ចដំណើរការពិភាក្សាកន្លងមក គ្រប់ពេលទាំងអស់យើងមិនទាន់ឮសោះ ទើបតែឮថ្ងៃនេះទេថាលោកអត់បានដឹងថា អង្គជំនុំជម្រះនឹងប្រាប់ជម្រាបទៅភាគីឲ្យធ្វើអីខ្លះ ប៉ុន្មានសប្ដាហ៍មុន។ ហើយភាគីដែលពាក់ព័ន្ធទាំងអស់ដូចអត់មានដែលលើកសោះ ទើបតែលោកមួយគត់ដែលលើកបញ្ហានេះ។

ប៉ុន្តែថ្ងៃនេះយើងទុកម្ដុំសិន បញ្ហានេះយើងទុកជជែកគ្នានៅពេលក្រោយ នៅពេលរៀបចំសវនាការមួយដោយឡែកផ្សេងទៀតទេ។ ប៉ុន្តែឥឡូវនេះកម្រិតត្រឹមតែលោកកត់សម្គាល់ ឬក៏មានអ្វីដែលឆ្លើយតបជាមួយនឹងអ្វីដែលលើកឡើងដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិនេះដែរឬទេ?

បើមានបញ្ហាទៀត យើងនឹងធ្វើសវនាការតទៀត យើងដើម្បីសម្រាកសិន ហើយនិងបន្តសវនាការទៀត។

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ ទាក់ទងទៅនឹងសំណើរបស់សហព្រះរាជអាជ្ញានេះ ខ្ញុំមិនយល់ទេអម្បាញ់មិញនេះ មិនដឹងថាគាត់ស្នើអ្វី។ អ៊ីចឹងខ្ញុំមិនអាចឆ្លើយតបទៅគាត់បានទេ អំមិញនេះខ្ញុំគ្រាន់តែយល់ថាគាត់ចង់កត់សម្គាល់ការដែលថា គាត់មិនលះបង់សិទ្ធិចោទសំណួរទៅលោក ខៀវ សំផន នោះទេ។ អ៊ីចឹងខ្ញុំមិនមានប្រតិកម្មអី មិនដឹងថាឆ្លើយតបអីជាក់លាក់ទៅគាត់នោះទេ។

[១០:៤៩:00]

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ ឲ្យប្តូរសិនទៅ ប្តូរបន្ថែម។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៥៤:៣២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រគល់ភារជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីសួរសំណួរមួយចំនួន ហើយនិងឆ្លើយបញ្ជាក់ជម្រាបជូនទៅភាគីពាក់ព័ន្ធដើម្បីយល់ជ្រួតជ្រាបអំពីបញ្ហាទាំងឡាយរបស់អង្គជំនុំជម្រះ។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

មានបញ្ហាចំនួនពីរដែលលោកប្រធានឲ្យខ្ញុំផ្ដល់ជាយោបល់លើចំណុចទាំងពីរនេះ។ ចំណុចទាំងពីរនេះគឺវាពាក់ព័ន្ធគ្នា។ ទី១ គឺបញ្ហាដែលលើកឡើងដោយតំណាងសហព្រះរាជអាជ្ញាដែលធ្វើឲ្យអង្គជំនុំជម្រះដឹងអំពីសំណួរជាក់លាក់នេះ ចំពោះលោក នួន ជា និង ខៀវ សំផន។ ថាតើជនជាប់ចោទទាំងពីរ

មានគោលបំណងនៅតែរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបដែរឬទេ? ឬក៏ជនជាប់ចោទមានឆន្ទៈឆ្លើយតបទៅនឹងសំណួរ។ លោក ខៀវ សំផន ប្រហែលជាអាចបញ្ជាក់លើចំណុចនេះនាពេលនេះបាន។ លោកនួន ជា ប្រហែលជាត្រូវការពេលវេលាបន្ថែមទៀតសម្រាប់ឆ្លើយតប។ ហើយក្រុមមេធាវីការពារក្ដីអាចផ្ដល់ជាការជូនដំណឹងដល់អង្គជំនុំជម្រះ ថាតើត្រូវការរយៈពេលប៉ុន្មានដើម្បីឆ្លើយតបទៅនឹងសំណួរនេះ។

[១០:៥៥:៥៦]

ពាក់ព័ន្ធទៅនឹងបញ្ហានៃការគ្រប់គ្រងសវនាការ ផ្ទុយពីអ្វីដែលលោក វែកគែន បានលើកឡើង អង្គជំនុំជម្រះសាលាដំបូងបានកំពុងរៀបចំសវនាការរៀបចំ វាត្រូវការពេលវេលាដែលត្រូវរៀបចំរបៀបវារៈ ហើយអង្គជំនុំជម្រះក៏ត្រូវការព័ត៌មានមូលដ្ឋានស្ដីពីសំណួរនានាដែលបានសួរក្នុងពេលនេះផងដែរ។ យើងខ្ញុំមានបំណងរៀបចំសវនាការ រៀបចំនេះគឺថានៅក្នុងពេលពីរសប្ដាហ៍ទៀត។ ហើយមេធាវីនិងភាគីទាំងអស់នឹងទទួលបានការជូនដំណឹងអំពីរបៀបវារៈទាំងអស់នេះភ្លាមៗក្រោយពេលដែលយើងបានជួបគ្នាដើម្បីបញ្ជាក់បំភ្លឺត្រង់ចំណុចទាំងអស់នេះ។ ក្នុងអំឡុងពេលសវនាការរៀបចំនោះ ប្រសិនបើជនជាប់ចោទណាមួយជ្រើសរើសសំណួរដែលត្រូវឆ្លើយតប យើងខ្ញុំនឹងសួរភាគី ថាតើត្រូវការពេលវេលាប៉ុន្មានដើម្បីសួរសំណួរទៅកាន់ជនជាប់ចោទទាំងពីររូប។

ហើយចំណុចចុងក្រោយខ្ញុំសូមគូសបញ្ជាក់ថា ខៀវ សំផន និង នួន ជា នឹងមានឱកាសក្នុងពេលធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយ។ នេះគឺជានីតិវិធីមួយដោយឡែក។ ដូច្នេះ តើនៅពេលនេះភាគីទាំងអស់យល់ហើយឬនៅ? ហើយលោក ខៀវ សំផន តើលោកនៅពេលនេះលោកមានលទ្ធភាពអាចឆ្លើយតបមកអង្គជំនុំជម្រះដែរឬទេ? តើលោកមានបំណងឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលលោកបានបញ្ជាក់ក្នុងពេលមុនៗនេះ ឬក៏លោកនៅតែរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប? សូមសួរទៅកាន់លោក ខៀវ សំផន។

ខ្ញុំសួរលោក ខៀវ សំផន មិនមែនសួរលោក វែកគែន ទេ។

[១០:៥៨:០២]

**លោក អាកទួរ វែកគែន៖**

បាទ ខ្ញុំដឹងថា លោកស្រីចៅក្រមសួរទៅលោក ខៀវ សំផន ហើយ។ ឥឡូវនេះខ្ញុំចង់ដឹងថាហេតុអីក៏មិនឲ្យយើងពិភាក្សាគ្នាសិន ព្រោះថា បញ្ហានេះបញ្ហាសំខាន់ណាស់ ព្រោះថាយើងមិនដឹងថាសាក្សីដែលនឹងមកផ្ដល់សក្ខីកម្មនោះមានសាក្សីអ្វីខ្លះ ហើយលោកចៅក្រមនិយាយថា លោក ខៀវ សំផន នេះ

ជាអ្នកធ្វើឲ្យរាំងស្ទះសវនាការទៅវិញ។

[១០:៥៨:៣៧]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

លោក វែកគែន មិនមែនសំណួរដែលខ្ញុំសួរ ដែលអង្គជំនុំជម្រះសួរនោះទេ ដើម្បីរៀបចំសវនាការដំណាក់កាលចុងក្រោយវាចាំបាច់ដែរ យើងត្រូវដឹងថាតើជនជាប់ចោទ មានចេតនា ឬបំណងក្នុងការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដែរឬទេ? ក្រោយពីយើងដឹងលើចម្លើយទាំងអស់នេះ គឺថាយើងនឹងរៀបចំពេលវេលាវាជាផ្នែកនៃការងារគ្រប់គ្រងតុលាការប្រចាំថ្ងៃ រួមទាំងលើបញ្ហាសាក្សីផងដែរ។ លោកនឹងទទួលបានដំណឹងក្រោយពេលដែលយើងទទួលបានព័ត៌មានចុងក្រោយ។

នៅពេលនេះសូមសួរទៅកាន់លោក ខៀវ សំផន។ ខ្ញុំសូមថ្លែងអំណរគុណ ប្រសិនបើលោកអាចជម្រាបជូនអង្គជំនុំជម្រះថាលោកអាចឆ្លើយតបទៅនឹងសំណួរនេះបានដែរឬទេ? អង្គជំនុំជម្រះនឹងធ្វើការសម្របសម្រួលការសុំអនុញ្ញាតពីលោក ប្រសិនបើលោកយល់ថាមិនអាចនិយាយក្នុងរយៈពេលយូរបាន។ យើងខ្ញុំនឹងពិចារណា។ ក៏ប៉ុន្តែយើងខ្ញុំចង់បានព័ត៌មានមូលដ្ឋានពីលោក ហើយសង្ឃឹមថាលោកយល់អំពីចំណុចនេះ។

[១១:00:00]

**លោក ខៀវ សំផន៖**

សូមគោរពលោកស្រីចៅក្រម សូមគោរពអស់លោក លោកស្រីចៅក្រមទាំងអស់។ រឿងនេះជារឿងកាត់ក្តីរបស់ខ្ញុំ ហើយការចោទប្រកាន់មកលើខ្ញុំវាសុទ្ធតែការចោទប្រកាន់ធ្ងន់ធ្ងរណាស់។ ហើយខ្ញុំក៏មិនសូវយល់នីតិក្រមរបស់តុលាការដែរទេ។ ដូច្នេះ ខ្ញុំសូមពេលវេលាពិគ្រោះពិភាក្សាជាមួយមេធាវីរបស់ខ្ញុំសិន។ ហើយខ្ញុំឆ្លើយជម្រាបទៅលោក សៅ នី ពីព្រឹកមិញនេះ ក៏ដោយខ្ញុំយល់មនោសញ្ចេតនាសោកសៅរបស់គាត់ ហើយខ្ញុំក៏ឆ្លៀតឱកាសដែលលោក សៅ នី បានអញ្ជើញមកនេះជម្រាបគាត់ដូចបានជម្រាបពីព្រឹកមិញយ៉ាងនេះតែប៉ុណ្ណោះទេ។ បាទ សម្រាបប៉ុណ្ណឹង សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:០១:៤៦]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ យើងកត់សម្គាល់នូវអ្វីដែលលោកបានឆ្លើយអម្បាញ់មិញលោកខៀវ

សំផន។ ជាការពិតលោកនឹងមានឱកាសសូមមតិប្រឹក្សាពីមេធាវីរបស់លោកក្នុងដំណើរការតុលាការនេះ។ យើងខ្ញុំឯកភាពយល់ស្របថា លោកនិង នួន ជា មានពេលវេលាត្រឹមថ្ងៃចន្ទ ម៉ោងប្រាំបួនព្រឹកជម្រាបអំពីសេចក្ដីសម្រេចរបស់លោក។

លោក កូប៉េ តើអាចទទួលយកបានទេ ពេលវេលាដែលផ្ដល់ជូនបែបនេះ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថា សមស្របហើយលោកស្រីចៅក្រម។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីចៅក្រម។ បាទ ហើយអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទទី២៧ ខែឧសភា ឆ្នាំ២០១៣ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃចន្ទ សប្ដាហ៍ក្រោយនេះអង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់ដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនដែលនឹងថ្លែងរៀបរាប់អំពីស្ថានភាពព្យសនកម្ម និងសេចក្ដីទុក្ខសោកវេទនារបស់ពួកគេនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយសូមភាគីនៃរឿងក្ដី និងសាធារណជនជ្រាប។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក ខៀវ សំផន និងលោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ទាំងពីររូបមកចូលរួមសវនាការនេះវិញនៅថ្ងៃចន្ទទី២៧ ខែឧសភា ឆ្នាំ២០១៣ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនគាត់មកនៅត្រឹមបន្ទប់ឃុំខ្លួនមួយនៅខាងក្រោមសាលសវនាការនេះដែលរៀបចំសម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ

*(សវនាការផ្អាកនៅម៉ោង ១១:០៣ នាទី)*